# ជំពូក ៦


តើអ្វីទៅជាអំពើហិង្សាផ្អែកយេនឌ័រ? ..... 142

**អំពើហិង្សាផ្អែកយេនឌ័របង្កគ្រោះថ្នាក់ដល់សុខភាពតាមរបៀបច្រើនយ៉ាង** ..... 143

អំពើហិង្សាផ្អែកយេនឌ័រប៉ះពាល់ដល់មនុស្សគ្រប់រូប ..... 144

ការសំដែងតួដើម្បីពិភាក្សាពីអំពើហិង្សាផ្អែកយេនឌ័រ ..... 146

សកម្មភាព៖ ការសំដែងតួ៖ អំពើហិង្សាផ្អែកយេនឌ័រប៉ះពាល់មនុស្សគ្រប់រូប ..... 148

សកម្មភាព៖ ហុចស្ពៃ ..... 149

**តើអ្វីទៅដែលបង្កឲ្យមានអំពើហិង្សាផ្អែកយេនឌ័រ?** ..... 150

សកម្មភាព៖ ស្វែងយល់ពីមូលហេតុនៃអំពើហិង្សាផ្អែកយេនឌ័រ ..... 152

សកម្មភាព៖ ការសំដែង "ការបញ្ចប់រឿងដោយភាពរីករាយ" ដើម្បីគិតអំពីការផ្លាស់ប្តូរ ..... 153

អំណាច និងអំពើហិង្សា ..... 154

សកម្មភាព៖ អំណាចខ្លាំង និង អំណាចតិច ..... 154

សកម្មភាព៖ ការចលនាឲ្យមានតុល្យភាពអំណាច ..... 156

**បុរសអាចជួយបញ្ឈប់អំពើហិង្សា** ..... 156

សកម្មភាព៖ បទពិសោធន៍ពីគម្រោងបុរសនៃក្រុងអូកលែន ..... 157

**សិល្បៈនិងសារព័ត៌មាន បំបែកភាពស្ងប់ស្ងាត់ចំពោះអំពើហិង្សា** ..... 162

ការចែករំលែករឿងរ៉ាវពិតអំពីអំពើហិង្សាតាមរយៈសិល្បៈ ..... 164

**សកម្មភាពសហគមន៍ដើម្បីគាំទ្រអ្នករួចរស់រានពីអំពើហិង្សា** ..... 166

គាំទ្រអ្នករួចរស់រាន ដើម្បីគេចចេញពីអំពើហិង្សាក្នុងគ្រួសារ ..... 166

បុគ្គលិកសុខាភិបាលគាំទ្រអ្នករួចរស់រានពីអំពើហិង្សាផ្លូវភេទ ..... 167

ក្រុមគាំទ្រគ្នាទៅវិញទៅមក ..... 168

**ការរៀបចំដើម្បីបង្ការអំពើហិង្សា** ..... 169

**កិច្ចប្រឹងប្រែងធ្វើឲ្យប្រព័ន្ធយុត្តិធម៌ដំណើរការ ដើម្បីបញ្ឈប់អំពើហិង្សា** ..... 171

សិក្សាពីការការពារផ្លូវច្បាប់ ..... 171

សកម្មភាព៖ ការស៊ើបអង្កេតជាក្រុមអំពីតួនាទីនៃអាជ្ញាធរមូលដ្ឋាន ..... 172

ធ្វើការងារជាមួយតុលាការនិងប៉ូលិស ..... 174

ការរៀបចំដើម្បីទាមទារយុត្តិធម៌សម្រាប់ជនដែលរួចរស់រាន ..... 175

# ការបញ្ចប់អំពើហិង្សាផ្នែកយេនឌ័រ




**ការរងគ្រោះពីអំពើហិង្សា** ឬការភ័យខ្លាចអំពើហិង្សា មិនគួរក្លាយជាផ្នែកមួយនៃជីវិតរបស់នរណាម្នាក់ឡើយ។ ជាអកុសល្យ អំពើហិង្សាផ្នែកយេនឌ័រមានយ៉ាងច្រើនរហូតដល់ថ្នាក់គេចាត់ទុកជារឿយៗថាជារឿង "ធម្មតា" ទៅហើយ។ ស្ត្រីភាគច្រើន ភ័យខ្លាចអំពើសេពសន្ថវៈ ឬហិង្សាផ្លូវភេទ សូម្បីតែពួកគេមិនធ្លាប់រងគ្រោះ ឬរងការគំរាមកំហែងក៏ដោយ។ ការភ័យខ្លាច នេះគឺជាផ្នែកមួយនៃភាពជាស្ត្រី។ ហើយបុរសខ្លះយល់ថា ការប្រើហិង្សា ឬការគំរាមប្រើហិង្សា គឺជាវិធីមួយដែលអាចទទួល យកបាន ដើម្បីប្រើប្រាស់អំណាចដែលសមស្រប ជាមួយនឹងការរំពឹងទុកអំពីភាពជាបុរស។ ការរំពឹងទុកទាំងនេះគឺជាផ្នែកមួយ នៃភាពជាបុរស សូម្បីតែបុរសមិនធ្លាប់ប្រើហិង្សាក៏ដោយ។

នៅពេលគិតអំពីអំពើហិង្សាផ្នែកយេនឌ័រ មនុស្សតែងតែគិតដល់អំពើហិង្សាផ្លូវកាយ ដូចជាការវាយដំ ឬអំពើហិង្សាផ្លូវភេទ ដូចជាការរំលោភសេពសន្ថវៈ ជាដើម។ អំពើហិង្សាផ្នែកយេនឌ័ររួមបញ្ចូលគ្រប់វិធីទាំងអស់ដែលគេប្រើប្រាស់អំណាចឬកម្លាំង ដើម្បីគ្រប់គ្រងលើស្ត្រីនិងក្មេងស្រី និងដើម្បីដាក់ទោសលើបុរសដែលមិនគោរពតាមនិយាមយេនឌ័រ។

# តើអ្វីទៅជាអំពើហិង្សាផ្នែកយេនឌ័រ?

អំពើហិង្សា ឬការគំរាមប្រើហិង្សាដែលប្រព្រឹត្តទៅលើស្ត្រីនិងក្មេងស្រី ដើម្បីអនុវត្តតួនាទីយេនឌ័រ គឺជាអំពើហិង្សាផ្នែកយេនឌ័រ។ ការបង្កគ្រោះថ្នាក់ចំពោះក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបី (LGBT) ក៏អាចជាអំពើហិង្សាផ្នែកយេនឌ័រផងដែរ ពីព្រោះជីវិតរបស់ពួកគេប្រឈមនឹងគំនិតរឹងរូសអំពីភាពជាបុរស និងភាពជាស្ត្រី។ អំពើហិង្សាផ្នែកយេនឌ័រមិនមែនត្រឹមតែជាអំពើហិង្សាផ្លូវកាយនិងផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអំពើហិង្សាផ្លូវអារម្មណ៍និងផ្លូវសេដ្ឋកិច្ចទៀតផង។ នៅពេលដែលគេបំពានដោយពាក្យសម្ដីទៅលើស្ត្រីនិងក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបី កំហិតសេរីភាពរបស់ពួកគេ ដកហូតសិទ្ធិទទួលបានការអប់រំ និងប្រាក់ឈ្នួលសមរម្យរបស់ពួកគេ ឬប្រើប្រាស់អំណាចក្នុងយេនឌ័រដើម្បីគ្រប់គ្រងអ្វីដែលពួកគេអាចនិងមិនអាចធ្វើទៅបាន នោះក៏ជាទម្រង់មួយនៃអំពើហិង្សាផងដែរ។







ជារឿយៗ អំពើហិង្សាផ្នែកយេនឌ័រមើលទៅដូចជាសកម្មភាពរបស់មនុស្សតែម្នាក់គត់ គឺបុរសដែលវាយដំប្រពន្ធរបស់គាត់ ឬថៅកែបៀតបៀនផ្លូវភេទបុគ្គលិករបស់គាត់។ ប៉ុន្តែ ពេលខ្លះអ្នកប្រព្រឹត្តត្រូវបានអនុញ្ញាត ឬថែមទាំងត្រូវបានលើកទឹកចិត្តឲ្យធ្វើវា ដោយសារតែអ្នកដទៃនៅជុំវិញខ្លួនគាត់គិតថាឥរិយាបថហិង្សាបែបនេះ គឺជារឿងអាចទទួលយកបាន។ ការដោះស្រាយអំពើហិង្សាផ្នែកយេនឌ័រមិនមែនមានត្រឹមតែការផ្លាស់ប្តូរសកម្មភាពរបស់បុរសចំពោះស្ត្រី និងក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបីប៉ុណ្ណោះទេ គឺថែមទាំងរួមបញ្ចូលផងដែរនូវការផ្លាស់ប្តូរច្បាប់ ផ្នត់គំនិត និងទំនៀមទម្លាប់ដែលអនុញ្ញាតនិងលើកទឹកចិត្តដល់អំពើហិង្សាផ្នែកយេនឌ័រ។

# អំពើហិង្សាផ្នែកយេនឌ័របង្កគ្រោះថ្នាក់ដល់សុខភាពតាមរបៀបច្រើនយ៉ាង



មានស្ត្រីយ៉ាងតិចម្នាក់ក្នុងចំណោមស្ត្រីពនាក់ ត្រូវបានវាយដំ បង្ខំឲ្យរួមភេទ ឬបំពានរាងកាយតាមរបៀបផ្សេងៗទៀត ដែលជាធម្មតាប្រព្រឹត្តដោយបុរសដែលនាងស្គាល់។ ផលប៉ះពាល់លើសុខភាពដោយសារអំពើហិង្សាផ្លូវកាយប្រភេទនេះ រួមមានការឈឺចាប់ធ្ងន់ធ្ងរ ពិការភាពអចិន្ត្រៃយ៍ និងរបួសដូចជាបាក់ឆ្អឹង រលាក ដាំភ្នែក មុត និងជាំជាដើម។



មានស្ត្រីជាច្រើនបានរលូតកូនដោយសាររងការវាយដំក្នុងអំឡុងពេលមានផ្ទៃពោះ។ បញ្ហាដូចជាឈឺក្បាល ហឺត ឈឺពោះ និងឈឺសាច់ដុំអាចនឹងបន្តអូសបន្លាយរយៈពេលយូរឆ្នាំក្រោយការវាយដំ។

ការរំលោភផ្លូវភេទបង្កបញ្ហាសុខភាពផ្លូវភេទដូចជា ការមានផ្ទៃពោះដែលមិនចង់បាន ជំងឺកាមរោគ ការភ័យខ្លាចក្នុងការរួមភេទ ការឈឺចាប់ក្នុងពេលរួមភេទ និងការបាត់បង់ចំណង់ផ្លូវភេទ។ ការរំលោភផ្លូវភេទលើកុមារអាចបង្កឲ្យមានអារម្មណ៍ភាន់ច្រឡំអំពីការរួមភេទនៅពេលពួកគេធំឡើង និងភ័យខ្លាចក្នុងការមានទំនាក់ទំនងផ្លូវភេទប្រកបដោយសុខភាពល្អ។



ការបដិសេធមិនផ្តល់ប្រាក់កាសដល់ស្ត្រីសម្រាប់ផ្គត់ផ្គង់ខ្លួននាង និងកូនៗរបស់នាង ឬការបដិសេធមិនផ្តល់ចំណីអាហារដល់ពួកគេ គឺជាទម្រង់មួយនៃអំពើហិង្សាផ្លូវសេដ្ឋកិច្ច។

ទម្រង់ខ្លះនៃអំពើហិង្សាមិនបង្កសញ្ញារងរបួសខាងក្រៅនោះទេ ប៉ុន្តែពួកវានៅតែបង្កគ្រោះថ្នាក់ចំពោះសុខភាពតាមរបៀបច្រើនយ៉ាង។ ឧទាហរណ៍ ច្បាប់ និងទំនៀមទម្លាប់អំពីការរៀបការ អាចជាទម្រង់មួយនៃអំពើហិង្សា ប្រសិនបើស្ត្រីត្រូវបានបង្ខំឲ្យទទួលយកតួនាទីមួយដែលនាងមានសិទ្ធិតិចតួចបំផុត។ ឋានៈទាបរបស់នាងក្នុងអាពាហ៍ពិពាហ៍ អាចបង្កគ្រោះថ្នាក់ដល់សុខភាពរបស់នាង ប្រសិនបើវាធ្វើឲ្យនាងខ្វះចំណីអាហារ និងការថែទាំសុខភាព ឬត្រូវបានបង្ខំឲ្យរួមភេទ ឬបង្ខំឲ្យមានផ្ទៃពោះ។ ឋានៈទាបរបស់នាងអាចបង្កគ្រោះថ្នាក់ដល់សុខភាពរបស់នាងដោយប្រយោល ប្រសិនបើវាធ្វើឲ្យនាងបាត់បង់ការអប់រំ រារាំងមិនឲ្យធ្វើការក្រៅផ្ទះ ឬបង្ខំឲ្យនាងធ្វើការបានប្រាក់ឈ្នួលទាប។ ជារឿយៗ លក្ខខណ្ឌទាំងនេះបង្ខំឲ្យស្ត្រីត្រូវបន្តស្ថិតក្នុងស្ថានភាពហិង្សាដែលអាចបង្កគ្រោះថ្នាក់ចំពោះសុខភាពរបស់ពួកនាង។



ការជេរប្រមាថ និងការស្តីបន្ទោសស្ត្រីដោយសារបញ្ហាគ្រួសារ គឺជាទម្រង់មួយនៃអំពើហិង្សាផ្លូវអារម្មណ៍ដែលបង្កគ្រោះថ្នាក់យូរអង្វែង។

អំពើហិង្សាផ្លូវអារម្មណ៍ ដូចជាបុរសជេរប្រមាថ មើលងាយ បន្ទះបង្អាប់ស្ត្រី ឬហាមឃាត់នាងមិនឲ្យចេញពីផ្ទះ មិនឲ្យទៅសួរសុខទុក្ខគ្រួសារ ឬមិនឲ្យនិយាយជាមួយមិត្តភ័ក្តិ ក៏ជាការគ្រោះថ្នាក់ផងដែរ។ ការបំពាននេះអាចធ្វើឲ្យស្ត្រីមានអារម្មណ៍ថា នាងមិនអាចធ្វើអ្វីដោយខ្លួនឯងបាន ឬមិនអាចចាកចេញពីស្ថានភាពបំពាននេះបាន។ នាងមិនអាចស្វែងរកសេវាថែទាំសុខភាព និងអាច រងគ្រោះពីបញ្ហាផ្លូវអារម្មណ៍យូរអង្វែង។

ការបំពានអាចនាំឲ្យមានបញ្ហាសុខភាពផ្លូវចិត្ត ដូចជាភ័យខ្លាចឥតឈប់ បាក់ទឹកចិត្ត ខ្វះការជំរុញទឹកចិត្ត ការឲ្យតម្លៃទាបលើខ្លួនឯង ភាពខ្មាសអៀន ស្តីបន្ទោសខ្លួនឯង និងបញ្ហាហូបចុកនិងដំណេក។ ដើម្បីទប់ទល់នឹងអំពើហិង្សាឬអារម្មណ៍ទាំងអស់នេះ ស្ត្រីប្រព្រឹត្តនូវទង្វើប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ដូចជាគេចមុខពីអ្នកដទៃ ប្រើប្រាស់ថ្នាំញៀនឬគ្រឿងស្រវឹង មានដៃគូរួមភេទច្រើន បង្ករបួសស្នាមលើខ្លួនឯង ឬធ្វើអត្តឃាតជាដើម។

ស្ត្រីឃាតគឺជាអំពើសម្លាប់ស្ត្រីដោយចេតនា។ ស្ត្រីឃាតរួមមានអំពើឃាតកម្មលើស្ត្រីប្រព្រឹត្តដោយដៃគូ ឬអតីតដៃគូរបស់នាង ដែលជាធម្មតាស្ថិតក្នុងទំនាក់ទំនងជាមួយលំនាំនៃការបំពានឥតឈប់។ អំពើស្ត្រីឃាតមួយប្រភេទទៀតគឺ "ការសម្លាប់ដើម្បីកិត្តិយស" ដែលកើតឡើងនៅពេលដែលសាច់ញាតិបុរសរបស់ស្ត្រី សម្លាប់នាងដោយសារតែនាងត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើផ្លូវភេទ ឬអំពើសង្គមណាមួយដោយគ្មានការអនុញ្ញាត ហើយពេលខ្លះទៀតដោយសារតែនាងទទួលរងនូវអំពើរំលោភ សេពសន្ថវៈ។ នៅក្នុងប្រទេសឥណ្ឌា ជារៀងរាល់ឆ្នាំមានស្ត្រីរាប់ពាន់នាក់ត្រូវបានធ្វើឃាតដោយសាច់ថ្លៃរបស់ពួកគេដោយសារតែមានជម្លោះរឿងជំនូនអាពាហ៍ពិពាហ៍ (ជាប្រាក់ដែលគ្រួសារស្ត្រីត្រូវបង់នៅពេលនាងរៀបការ)។ ហើយមានស្ត្រីរាប់មិនអស់ដែលត្រូវបានវាយប្រហាររំលោភសេពសន្ថវៈ និងធ្វើឃាតដោយបុរសដែលមិនត្រូវបានកំណត់អត្តសញ្ញាណ ជាពិសេសនៅតាមទីកន្លែងដែលបុរសជាច្រើនពាក់ព័ន្ធនឹងអំពើជួញដូរគ្រឿងញៀន និងជម្លោះប្រដាប់អាវុធ។




នៅក្នុងប្រទេសម៉ិកស៊ិក្កូ ក្រុមអង្គការសិទ្ធិមនុស្សបានដាក់តាំងស្បែកជើងទទេរបស់ស្ត្រីដែលបានបាត់ខ្លួន ឬដែលសាកសពរបស់ពួកនាងត្រូវបានគេប្រទះឃើញក្រោយអំពើឃាតកម្មដ៏សាហាវ។ អាជ្ញាធរបានចាត់វិធានការតិចតួចដើម្បីបញ្ឈប់អំពើហិង្សានោះ។

# អំពើហិង្សាផ្អែកយេនឌ័រប៉ះពាល់ដល់មនុស្សគ្រប់រូប

អំពើហិង្សាមិនប៉ះពាល់តែចំពោះបុគ្គលដែលរងគ្រោះនោះទេ វាក៏បង្កផលប៉ះពាល់ចំពោះមនុស្សគ្រប់រូបផ្សេងទៀតផងដែរ។ អំពើហិង្សាផ្អែកយេនឌ័រជំរុញមិនឲ្យមានទំនាក់ទំនងប្រកបដោយការគោរពនិងសុខភាពល្អនៅក្នុងគ្រួសារ សាលារៀន ទីសាធារណៈ និងសូម្បីតែនៅតាមមណ្ឌលសុខភាព។ ដរាបណាមនុស្សនៅតែជឿថា បុរសសំខាន់ជាងស្ត្រី ហើយស្ត្រីសមនឹងត្រូវបុរសវាយដំ បន្ទះបង្អាប់ និងដកហូតសិទ្ធិឬធនធាន នោះគ្រប់គ្នាក្នុងសង្គមនឹងរងគ្រោះពីអំពើអយុត្តិធម៌នេះតាមរបៀបជាច្រើន។

អំពើហិង្សាធ្វើឲ្យកុមារ គ្រួសារ និងសហគមន៍បាត់បង់ស្ត្រីដែលមានសុខភាពល្អ អាចបំពេញតួនាទីពេញលេញ និងអាចចូលរួម និងរួមចំណែកអភិវឌ្ឍគ្រួសារនិងសង្គម។ ស្ត្រីដែលរងការបំភិតបំភ័យ ឬបាក់ស្បាត មិនអាចដើរតួនាទីសកម្មណាមួយក្នុងការកែលម្អសុខភាព និងលើកកម្ពស់ឋានៈរបស់ស្ត្រីនៅក្នុងសហគមន៍បានឡើយ។

អំពើហិង្សាផ្អែកយេនឌ័រជួយពង្រឹងគំនិតប្រកបដោយគ្រោះថ្នាក់ដែលថា ភាពជាបុរសត្រូវតែប្រព្រឹត្តអំពើហិង្សា។ គំនិតនេះលើកទឹកចិត្តឲ្យបុរសធ្វើសកម្មភាពបែបហិង្សា ដែលអាចនាំឲ្យមានរបួសស្នាម និងមរណភាពកាន់តែច្រើន។

## អំពើហិង្សាផ្នែកយេនឌ័រប៉ះពាល់ដល់កុមារ



ជារឿយៗ កុមារដែលរងគ្រោះឬដែលមើលឃើញអំពើហិង្សាជាប្រចាំ តែងតែមានអារម្មណ៍អស់សង្ឃឹម ខឹងសម្បា ក្រៀមក្រំ ខ្មាសអៀន ឬមានកំហុស។ អារម្មណ៍ទាំងនេះអាចនឹងនាំឲ្យពួកគេមានចរិតកោងកាច និងបំពានលើអ្នកដទៃដោយចម្លងយកនូវអំពើហិង្សាដែលពួកគេបានឃើញ។ សុបិនអាក្រក់ និងការភ័យខ្លាចផ្សេងទៀត ការដេកនោម និងបញ្ហាផ្លូវអារម្មណ៍តែងកើតមានជាទូទៅ ហើយអាចក្លាយជាបញ្ហាសុខភាពរយៈពេលយូរអង្វែងទៀតផង។ កុមារមួយចំនួនក្លាយជាមានចរិតស្ងៀមស្ងាត់ និងមិនលេងជាមួយក្មេងដទៃ ដោយសារតែពួកគេភ័យខ្លាចក្នុងការនិយាយស្តី ឬប្រព្រឹត្តអ្វីមួយដែលអាចនាំឲ្យមានអំពើហិង្សា ឬដោយសារតែពួកគេភ័យខ្លាចក្នុងការប្រាប់នរណាម្នាក់អំពីអ្វីដែលបានកើតឡើងចំពោះពួកគេ។

ជារឿយៗ កុមារនៅក្នុងគ្រួសារប្រើអំពើហិង្សា ធំធាត់និងរៀនសូត្រយឺតជាងក្មេងដទៃ។ ពួកគេអាចនឹងមានបញ្ហាផ្តោតអារម្មណ៍ក្នុងសាលារៀន និងមានជំងឺជាច្រើន ដូចជាឈឺពោះ ឈឺក្បាល និងហឺតជាដើម។ ហើយមានកុមារជាច្រើនបានរងរបួស និងស្លាប់នៅពេលពួកគេទទួលរងអំពើហិង្សា។



ក្មេងស្រីនិងក្មេងប្រុសរៀនពីតួនាទីយេនឌ័រ ពីមនុស្សធំនៅជុំវិញខ្លួនពួកគេ។ ប្រសិនបើបុរសប្រើហិង្សាលើស្ត្រី ហើយស្តីបន្ទោសស្ត្រី នោះក្មេងប្រុសនឹងរៀនអនុវត្តដូចគ្នាដែរ។ ប្រសិនបើស្ត្រី ស្តីបន្ទោសខ្លួនឯង នោះក្មេងស្រីក៏រៀនមានអារម្មណ៍ដូច្នោះផងដែរ។ ក៏ប៉ុន្តែអំពើហិង្សាលើស្ត្រីមិនមែនជាកំហុសរបស់នាងទេ។

សកម្មភាពសំដែងតួនៅក្នុងទំព័រ 148 អាចជួយក្រុមឲ្យស្វែងយល់និងពិភាក្សាពីរបៀបដែលអំពើហិង្សាផ្នែកយេនឌ័រប៉ះពាល់ដល់មនុស្សគ្រប់រូប ទាំងជនរងគ្រោះ ជនដែលមើលឃើញអំពើហិង្សា និងអ្នកដែលប្រើអំពើហិង្សានោះផងដែរ។



ខ្ញុំបានមើលឃើញឪពុករបស់ខ្ញុំវាយដំម្តាយខ្ញុំតាំងពីខ្ញុំនៅតូច ដូច្នេះខ្ញុំគិតថាវាជារឿងធម្មតាទៅហើយ។ នៅពេលដែលខ្ញុំរៀនសូត្រអំពីអំពើហិង្សា ខ្ញុំក៏បានយល់ថាវាបង្កគ្រោះថ្នាក់ចំពោះមនុស្សគ្រប់រូបប៉ុណ្ណា ហើយខ្ញុំក៏ឈប់វាយធ្វើបាបប្រពន្ធរបស់ខ្ញុំ។ ខ្ញុំមិនដឹងនិយាយប្រាប់រឿងនេះដល់ប្រពន្ធខ្ញុំរបៀបណានោះទេ ហើយរយៈពេលយ៉ាងយូរក្រោយមកទើបនាងជឿជាក់លើខ្ញុំ។

# ការសំដែងតួដើម្បីពិភាក្សាពីអំពើហិង្សាផ្នែកយេនឌ័រ

អ្នកចូលរួមក្នុងការសំដែងតួ សំដែងនូវស្ថានភាពជាក់ស្តែងក្នុងជីវិត។ ការសំដែងនេះជួយឲ្យពួកគេពិភាក្សាពីប្រធានបទដែលពួកគេមានអារម្មណ៍ថាជារឿងឯកជនឬផ្ទាល់ខ្លួន ដូចជាតួនាទី និងទំនាក់ទំនងរបស់បុរស និងស្ត្រីនៅក្នុងគ្រួសារ។ សកម្មភាពនៅទំព័រ 148, 152 ដល់ 153 និង 160 នៅក្នុងជំពូកនេះ ប្រើប្រាស់ការសំដែងតួអំពីអំពើហិង្សាផ្នែកយេនឌ័រ ដើម្បីជួយឲ្យពួកគេគិតអំពីមូលហេតុដែលនាំឲ្យកើតមានអំពើហិង្សា និងអំពីរបៀបដែលអំពើហិង្សានាំឲ្យមានគ្រោះថ្នាក់។ ការពិភាក្សាពីការសំដែងតួអាចជួយក្រុមឲ្យពិនិត្យមើលឥរិយាបថ ទំនៀមទម្លាប់ និងលំអានក្នុងវិធីដែលបុរស និងស្ត្រីប្រព្រឹត្តចំពោះគ្នា និងគិតអំពីវិធីធ្វើការរួមគ្នាដើម្បីបញ្ឈប់អំពើហិង្សាផ្នែកយេនឌ័រ និងផ្លាស់ប្តូរគំនិត និងទំនៀមទម្លាប់ដែលនាំឲ្យមនុស្សយល់ថាអំពើហិង្សាជារឿងធម្មតា។

អ្នកអាចជ្រើសរើសធ្វើសកម្មភាពទាំងនេះដាច់ដោយឡែកពីគ្នា ឬជាបន្តបន្ទាប់។ ដំបូង អ្នកប្រហែលជាចង់ពិភាក្សាពីតួនាទីយេនឌ័រជាមួយនឹងក្រុម (សូមមើលជំពូក៣ ៖ យេនឌ័រនិងសុខភាព)។

សកម្មភាពទាំងនេះអាចដំណើរការទៅបានល្អជាមួយនឹងការសហការគ្នារវាងស្ត្រីនិងបុរសមួយក្រុម។ ការឲ្យបុរសសំដែងតួជាស្ត្រី ហើយស្ត្រីដើរតួជាបុរស អាចជួយឲ្យប្រជាជនគិតអំពីវិសមភាព និងយេនឌ័រតាមរបៀបថ្មីមួយ។

## ការរៀបចំការសំដែងតួ

រៀបចំស្ថានភាព (សាច់រឿង) ជាមុន។ ចូរព្យាយាមច្នៃបង្កើតស្ថានភាពដែលអាចឲ្យជឿបាន ប៉ុន្តែមិនត្រូវបង្ហាញហិង្សាឬការរំជួលចិត្តខ្លាំងពេកនោះទេ។ ការសំដែងតួនឹងមើលទៅកាន់តែដូចស្ថានភាពពិត ប្រសិនបើអ្នកប្រមូលគ្រឿងតែងឆាក និងសម្លៀកបំពាក់មួយចំនួនដែលអ្នកសំដែងអាចប្រើប្រាស់ដើម្បីបង្ហាញពីតួនាទីដែលពួកគេកំពុងសំដែង។ ឧទាហរណ៍សម្រាប់ស្ថានភាពខាងក្រោមរួមមានដូចជា កាបូបដើរផ្សារ ក្រវ៉ាត់ក មួកបុរស ម៉ាស៊ីនដេរ ស្គរគ្រាប់ និងគ្រឿងអលង្ការ។

ខាងក្រោមនេះគឺជាស្ថានភាពគំរូមួយចំនួន ៖

### ស្ថានភាពទី១

**តួសំដែង**

អ្នកប្រើហិង្សា ៖ ប្តី

ជនរងគ្រោះ ៖ ប្រពន្ធ

សាក្សី ៖ កូនៗ និងប្អូនស្រីប្រពន្ធ



ប្រពន្ធមកផ្ទះយឺតដោយសារចូលរួមការប្រជុំសហគមន៍។ ប្តីរបស់នាងជួបរឿងស៊យនៅថ្ងៃនេះ ហើយមានអារម្មណ៍ខឹងសម្បាដោយសារតែមិនមាននរណារៀបចំអាហារពេលល្ងាចសម្រាប់គាត់នៅពេលគាត់ត្រឡប់មកដល់ផ្ទះ។ ប្អូនស្រីរបស់នាងកំពុងមើលថែកូនៗរបស់ពួកគេ។ ពួកគេទាំងអស់គ្នានៅក្នុងផ្ទះនោះកំពុងរង់ចាំប្រពន្ធគាត់ត្រឡប់មកផ្ទះវិញ។ តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងនាពេលបន្ទាប់?

## ស្ថានភាពទី២

**តួសំដែង**

អ្នកប្រើហិង្សា ៖ ថៅកែរោងចក្រ

ជនរងគ្រោះ ៖ កម្មការិនី

សាក្សី ៖ កម្មករ-កម្មការិនីដែលចូលទៅបើកប្រាក់ឈ្នួលមុន ហើយចាកចេញពីកន្លែងកើតហេតុ

កម្មការិនីវ័យក្មេងម្នាក់បានធ្វើការរយៈពេល១សប្តាហ៍ នៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់តូចមួយ។ នៅពេលនាងទៅបើកប្រាក់ឈ្នួលរបស់នាង ថៅកែប្រាប់ឲ្យនាងមកបើកនៅពេលក្រោយ។ គាត់បានឲ្យនាងរង់ចាំរហូតដល់គ្រប់គ្នាចាកចេញពីរោងចក្រ ហើយក៏ហៅនាងចូលទៅក្នុងការិយាល័យរបស់គាត់តែម្នាក់ឯង។ តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងនាពេលបន្ទាប់?



## ស្ថានភាពទី៣

**តួសំដែង**

អ្នកប្រើហិង្សា ៖ ក្មេងប្រុសជំទង់

ជនរងគ្រោះ ៖ ក្មេងស្រីជំទង់

សាក្សី ៖ ក្មេងប្រុសជំទង់ដទៃទៀត

ក្មេងស្រីជំទង់ម្នាក់ចូលចិត្តស្លៀកពាក់ដូចមនុស្សប្រុសជាជាងស្លៀកសំពត់បែបប្រពៃណី ឬសម្លៀកបំពាក់ដែលស្ត្រីវ័យក្មេងភាគច្រើនស្លៀក។ នៅពេលដែលនាងកំពុងដើរទៅផ្ទះម្នាក់ឯង នាងក៏ដើរកាត់ក្មេងប្រុសជំទង់មួយក្រុម ហើយពួកគេក៏ចាប់ផ្តើមស្រែកចម្អកដាក់នាង។ ក្មេងប្រុសជំទង់ម្នាក់ក៏បានដើរតាមពីក្រោយនាង។ តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងនាពេលបន្ទាប់?





*ស្ថានភាពសម្រាប់សំដែងតួដែលមានបញ្ចូលអំពើហិង្សាអាចនឹងបង្កការលំបាក ឬការរំជួលចិត្តសម្រាប់អ្នកចូលរួមមួយចំនួន ជាពិសេសប្រសិនបើវានិយាយអំពីអំពើហិង្សាដែលពួកគេធ្លាប់បានរងគ្រោះដោយខ្លួនឯងផ្ទាល់ ឬទម្រង់នៃអំពើហិង្សាដែលពួកគេមិនទាន់បានពិចារណាទៅដល់ ដូចជាអំពើហិង្សាលើក្រុមបុរសស្រឡាញ់បុរស ឬការរំលោភសេពសន្ថវៈដោយប្តី/ប្រពន្ធ។*

## សកម្មភាព ការសំដែងតួៈ អំពើហិង្សាផ្អែកយេនឌ័រប៉ះពាល់មនុស្សគ្រប់រូប

1. បែងចែកអ្នកចូលរួមជាក្រុមតូចៗដែលមានគ្នាប្រហែល ៥នាក់។ ផ្តល់ឲ្យក្រុមនីមួយៗនូវសេចក្តីបរិយាយខ្លីមួយអំពីស្ថានភាពណាមួយ ដូចជាស្ថានភាពដែលបានលើកឡើងនៅទំព័រមុន ដែលអាចឈានទៅដល់អំពើហិង្សា។ (អ្នកអាចផ្តល់ការណែនាំខ្លះៗអំពីការមិនពណ៌នាស៊ីជម្រៅអំពីអំពើហិង្សានៅក្នុងសាច់រឿងនោះ) ស្នើឲ្យពួកគេចំណាយពេល ១៥-២០នាទីដើម្បីរៀបចំសាច់រឿងមួយដែលមានរយៈពេល៥នាទី ដែលសំដែងអំពីស្ថានភាពនោះ និងអ្វីដែលពួកគេគិតថានឹងកើតឡើង។ លើកទឹកចិត្តឲ្យសមាជិកក្រុមគ្រប់រូបចូលរួមទាំងអស់គ្នា។

2. ស្នើឲ្យក្រុមនីមួយៗឡើងសំដែងសាច់រឿងរបស់ខ្លួន។

3. ក្រោយពីក្រុមទាំងអស់សំដែងចប់ ស្នើឲ្យក្រុមទាំងអស់ទុកដាក់គ្រឿងតុបតែងឆាកនិងសម្លៀកបំពាក់សំដែងនៅកន្លែងមួយ។ បន្ទាប់មក ស្នើឲ្យសមាជិកទាំងនោះបង្កើតក្រុមថ្មីចំនួន៣ ដោយផ្អែកលើតួនាទីរបស់ពួកគេក្នុងនាមជា "ជនរងគ្រោះ" "អ្នកប្រើហិង្សា" និង "សាក្សី។ ស្នើឲ្យអ្នកចូលរួមក្នុងក្រុមនីមួយៗពណ៌នាអំពីអារម្មណ៍របស់ពួកគេក្នុងពេលសំដែងតួ។

4. ស្នើឲ្យក្រុមនីមួយៗក្នុងចំណោមក្រុមទាំង៣ និយាយពីយោបល់របស់ពួកគេទាក់ទងនឹងអំពើហិង្សាដែលបានជះឥទ្ធិពលទៅលើតួអង្គដែលពួកគេសំដែង។ តើវាអាចនឹងបង្កគ្រោះថ្នាក់អ្វីខ្លះ?




5. សួរអ្នកចូលរួមពីអារម្មណ៍របស់ពួកគេនៅពេលទស្សនាការសំដែងរបស់ក្រុមផ្សេង តើពួកគេរងផលប៉ះពាល់ដោយរបៀបណា?

6. ជាចុងក្រោយ ស្នើឲ្យក្រុមទាំងអស់រួមគ្នាជជែកអំពីវិធីផ្សេងៗដែលអំពើហិង្សាផ្អែកយេនឌ័របង្កផលប៉ះពាល់ចំពោះស្ត្រីនៅក្នុងការសំដែងតួទាំងនេះ។ សង្ខេបគំនិតរបស់ក្រុមអំពីរបៀបដែលអំពើហិង្សាក្នុងការសំដែងតួក៏អាចបង្កផលប៉ះពាល់ចំពោះកូនៗរបស់ស្ត្រី គ្រួសាររបស់នាង និងអ្នកដទៃដែលមើលឃើញការប្រើអំពើហិង្សា និងសហគមន៍ទាំងមូលផងដែរ។ បន្ទាប់មក អ្នកអាចបន្តការពិភាក្សាអំពីមូលហេតុនៃអំពើហិង្សាផ្អែកយេនឌ័រ (ប្រើប្រាស់សកម្មភាពនៅទំព័រ ១៥២-១៥៣ ឬការពិភាក្សាអំពីរបៀបដែលតួនាទីរបស់តួសំដែងអាចធ្វើការផ្លាស់ប្តូរដើម្បីបង្ការអំពើហិង្សាដោយប្រើប្រាស់សកម្មភាពនៅទំព័រ 153)។

## វាយតម្លៃការសំដែងតួ

**សកម្មភាព** **ហុចស្ពៃ**

នៅពេលបញ្ចប់ការពិភាក្សានិងសកម្មភាពជាក្រុម ជាពិសេសអំពីប្រធានពិបាកៗ ជាការប្រសើរគួរស្នើឲ្យគ្រប់គ្នាជជែកអំពីអ្វីដែលពួកគេបានរៀនសូត្រ អារម្មណ៍ដែលពួកគេមានចំពោះបញ្ហា និងរបៀបដែលពួកគេទទួលបានការជំរុញទឹកចិត្តឲ្យធ្វើសកម្មភាពដើម្បីធ្វើការផ្លាស់ប្តូរ។ លើសពីនេះទៀត ជាការសំខាន់ផងដែរដែលត្រូវផ្តល់ឱកាសឲ្យអ្នកចូលរួមទាំងអស់ធ្វើការវាយតម្លៃ និងផ្តល់មតិត្រឡប់។ សកម្មភាពនេះគឺជាវិធីដ៏រីករាយមួយសម្រាប់បញ្ចូលអ្នកចូលរួមទាំងអស់ទៅក្នុងដំណើរការត្រិះរិះពិចារណា និងវាយតម្លៃ។

**ការត្រៀមលក្ខណៈ** ៖ ស្វែងរកក្រដាសសៀវភៅសរសេរ បង់ស្អិត និងប៊ិច។ ចូរសរសេរសំណួរវាយតម្លៃចំនួន៤ មួយឬច្រើនសំណុំខាងក្រោម នៅលើក្រដាសសៀវភៅដាច់ដោយឡែកពីគ្នា។

1. សរសេរឈ្មោះអ្វីមួយដែលយើងបានធ្វើ។
2. សរសេរឈ្មោះអ្វីមួយដែលអ្នកបានរៀនសូត្រ។
3. និយាយអ្វីមួយដែលអ្នកចូលចិត្ត និងនិយាយអ្វីមួយដែលអ្នកមិនចូលចិត្ត។
4. តើអ្នកនឹងធ្វើអ្វីជាមួយនឹងអ្វីដែលអ្នកបានរៀនសូត្រ?

❶ នៅពេលបញ្ចប់សកម្មភាពឬសិក្ខាសាលា សួរក្រុមថាតើសំណួរណាខ្លះដែលពួកគេគិតថាសំខាន់សម្រាប់យល់ពីប្រធានបទដែលអ្នកបានពិភាក្សា។ ចូរសរសេរសំណួរនីមួយៗនៅលើក្រដាសសៀវភៅដាច់ដោយឡែកមួយ។

❷ ចូរបង្កើត "ស្ពៃ" មួយដុំដោយខ្ទប់ក្រដាសសំណួរវាយតម្លៃចុងក្រោយ (លេខ៤) ទៅក្នុងបាល់ដ៏តឹងមួយ ហើយបន្ទាប់មកបន្ថែមស្រទាប់ក្រដាសនៅជុំវិញវា។ ជំនួសការបន្ថែមសន្លឹកសៀវភៅដែលមានសំណួរដែលក្រុមស្នើឡើង ជាមួយនឹងសំណួរវាយតម្លៃ និងសំណួរបញ្ឆោតមួយចំនួន ដូចជា "ចូរអ្នករាំ" ឬ "ចូរអ្នកច្រៀងចម្រៀងមួយបទ" រហូតអ្នកបានបង្កើតដុំស្ពៃមួយដែលមានទំហំដូចស្ពៃពិត។ ចូរប្រាកដថា អ្នកបានដាក់សំណួរវាយតម្លៃទាំងនោះតាមលេខរៀងពីធំមកតូច ដូច្នេះនៅពេលដែលស្ពៃត្រូវបានបក នោះគេនឹងអានសំណួរតាមលំដាប់លេខរៀង ១, ២, ៣, ៤ ។



❸ ចាក់បទភ្លេងឬទះដៃ និងស្នើឲ្យអ្នកចូលរួមហុចស្ពៃតគ្នាពីម្នាក់ទៅម្នាក់។ នៅពេលបទភ្លេងឈប់ អ្នកដែលកំពុងកាន់ស្ពៃត្រូវបកមួយសន្លឹក ហើយឆ្លើយសំណួរនៅក្នុងសន្លឹកក្រដាសនោះ។ បន្តធ្វើដូច្នេះរហូតដល់បកសន្លឹកសំណួរទាំងអស់ពីស្ពៃ។

**ចំណាំ៖** អ្នកអាចសរសេរពីអ្វីដែលពួកគេនិយាយនៅលើស្លឹកក្រដាសធំមួយដែលគ្រប់គ្នាអាចមើលឃើញ ឬគ្រាន់តែស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលគ្រប់គ្នានិយាយ។ តាមរយៈការគិតគូរពិចារណាអំពីអ្វីដែលគ្រប់គ្នានិយាយ អ្នកអាចរៀនសូត្របានច្រើនអំពីអ្វីទៅដែលមានប្រសិទ្ធភាពបំផុតពីសិក្ខាសាលា ហើយរបៀបដែលអាចកែលម្អសិក្ខាសាលានៅពេលក្រោយ។

# តើអ្វីទៅដែលបង្កឲ្យមានអំពើហិង្សាផ្នែកយេនឌ័រ?

ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី យើងចាំបាច់ត្រូវយល់ពីរបៀបដែលគំនិតប្រកបដោយគ្រោះថ្នាក់អំពីភាពជាបុរស និងភាពជាស្ត្រី ផ្តល់ជាមូលហេតុសម្រាប់ការប្រើប្រាស់អំពើហិង្សាដោយបុរសទៅលើស្ត្រី កុមារ និងអ្នកដទៃដែលមានឋានៈតូចទាបជាងខ្លួន។ ឋានៈមិនស្មើគ្នារវាងបុរសនិងស្ត្រីគឺជាមូលហេតុចម្បងនៃអំពើហិង្សាផ្នែកយេនឌ័រ។ វិសមភាពនេះរួមមានជំនឿដែលថា ស្ត្រីគួរពឹងផ្អែកផ្នែកសេដ្ឋកិច្ចលើបុរស និងថា ស្ត្រីនិងកុមារគឺជាកម្មសិទ្ធិរបស់បុរស និងស្ថិតក្រោមគ្រប់គ្រងរបស់បុរស។

### ស្ត្រីចែករំលែករឿងរ៉ាវ ទឹកភ្នែក និងកំហឹង

នៅក្នុងកិច្ចប្រជុំមួយស្តីអំពីការអប់រំសុខភាព នៅក្នុងទីក្រុងពូន (Pune) នៃប្រទេសឥណ្ឌា ស្ត្រីមួយក្រុមកំពុងលួងលោមនាង ម៉ាយ៉ា ដែលបានសម្រាលកូនស្រីទីបីរបស់នាង។ នាងយំខ្សឹកខ្សួលជាខ្លាំង ដោយបង្ហាញខ្នងហើមរបស់នាងឲ្យស្ត្រីទាំងនោះមើល។ នាង ខាឌីចា បានលាបប្រេងកូឡាឲ្យនាង ហើយបាននិយាយថា "កុំយំអី។ ប្តីខ្ញុំក៏វាយខ្ញុំដែរ ទោះជាខ្ញុំមានកូនប្រុសពីរនាក់ឲ្យគាត់ហើយក៏ដោយ។



ក្រោយពីស្ងប់ស្ងាត់បន្តិច នាង រដ្ឋា ក៏បាននិយាយថា "ប្តីខ្ញុំវាយខ្ញុំពេលដែលខ្ញុំតមាត់ទៅគាត់។ បុរសមិនចូលចិត្តឲ្យយើង និយាយតមាត់ទៅគេវិញទេ។ នាង ឌីផា ក៏សួរទាំងចម្ងល់ថា "ចុះហេតុអ្វីបានជាប្តីរបស់ មីនូ រុញច្រាននាងចេញពីផ្ទះដែរ? នាងមិនដែលនិយាយតមាត់អ្វីផង" គ្មាននរណាម្នាក់ឆ្លើយសំណួរនេះទេ។

បន្ទាប់មក អ្នកស្រី ភូណាម ដែលជាបុគ្គលិកសុខាភិបាលបាននិយាយថា "បុរសវាយស្ត្រីដើម្បីបង្ហាញថាពួកគេមានអំណាចមកលើយើង មិនមែនដោយសារកំហុសរបស់យើងទេ។ ប្តីរបស់ ចូយ៉ា និយាយថា គាត់វាយនាងដោយសារតែសម្បុរនាងខ្មៅពេក។ ប៉ុន្តែចុះសម្បុររបស់នាង រូផា វិញសណាស់មែនទេ? នាងត្រូវបានប្តីនាងដុតសម្លាប់ដោយសារតែគាត់ជាបុរសប៉ិនប្រចណ្ឌ" បរិយាកាសកិច្ចប្រជុំបានផ្លាស់ប្តូរក្រោយពីនោះមក។ អ្នកស្រី អាមីណា ដែលមានវ័យចំណាស់ជាងគេ បាននិយាយថា "ខ្ញុំពិតជាខឹងសម្បាខ្លាំងណាស់។ ខ្ញុំមើលឃើញថាមានហេតុផលស៊ីជម្រៅជាច្រើននៅពីក្រោយអំពើហិង្សាលើប្រពន្ធនេះ។

## ភាពខុសគ្នារវាងមូលហេតុ និង "កត្តាជំរុញ" ឱ្យមានអំពើហិង្សា

នៅពេលខ្លះ មនុស្សពន្យល់ពីមូលហេតុដែលបុរសម្នាក់ប្រព្រឹត្តអំពើហិង្សាដោយនិយាយថាគាត់ស្រវឹង ប្រច័ណ្ឌ ឬមិនសប្បាយចិត្ត។ លេសទាំងនេះអាចជាផ្នែកមួយនៃមូលហេតុ ប៉ុន្តែវាមិនមែនជារឿងរ៉ាវទាំងមូលនោះទេ។ ហើយពួកវាមិនមែនជាមូលហេតុសមស្របសម្រាប់ការប្រព្រឹត្តអំពើហិង្សានោះដែរ! មនុស្សមួយចំនួនហៅមូលហេតុទាំងនេះថា "កត្តាជំរុញ" ពីព្រោះពួកវាអាច "ជំរុញ" ឲ្យបុរសធ្លាក់ចូលក្នុងស្ថានភាពជាក់លាក់ណាមួយបាន។ ប៉ុន្តែពួកវាមិនបណ្តាលឲ្យបុរសគ្រប់រូបក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា ប្រើប្រាស់អំពើហិង្សានោះទេ។ ក្មេងប្រុសមិនមែនកើតមកដើម្បីប្រើអំពើហិង្សានោះឡើយ។

## វដ្តនៃហិង្សា

នៅពេលដែលទំនាក់ទំនងមួយឈានដល់ការប្រើហិង្សា ការវាយដំលើកទីមួយមើលទៅដូចជាព្រឹត្តិការណ៍ដាច់ដោយឡែកមួយ។ ប៉ុន្តែ នៅពេលដែលអំពើហិង្សានោះចេះតែកើតមានជាបន្តបន្ទាប់ ម្តងហើយម្តងទៀត នោះវានឹងដើរតាមលំនាំមួយនេះ ៖




ជាធម្មតា ស្ត្រីដែលមានទំនាក់ទំនងប្រកបដោយហិង្សា រៀនរំពឹងទុក និងថែមទាំងត្រៀមខ្លួនទទួលយកផ្នែកនីមួយៗនៃវដ្តហិង្សា។ សម្រាប់ប្តីប្រពន្ធជាច្រើន រយៈពេលស្ងាត់ស្ងៀមកាន់តែខ្លីទៅៗ ខណៈដែលស្ត្រីបាត់បង់ឆន្ទៈរបស់នាងក្នុងការប្រឆាំង ឬតបតចំពោះប្តីរបស់នាង។ ការគ្រប់គ្រងរបស់ប្តីទៅលើរូបនាង កាន់តែពេញលេញ រហូតដល់គាត់មិនចាំបាច់សន្យាអ្វីល្អៗចំពោះនាងទៀតឡើយ។

## ហេតុអ្វីបានជាស្ត្រីនៅតែទ្រាំ?

ស្ត្រីអាចធ្លាក់ខ្លួនជាប់ក្នុងអន្ទាក់នៃវដ្តហិង្សា។ ការផ្តាច់ខ្លួនចេញពីវដ្តហិង្សានេះគឺជាមធ្យោបាយមួយដើម្បីគេចចេញពីអំពើហិង្សា ប៉ុន្តែសម្រាប់ស្ត្រីរងគ្រោះជាច្រើន ការចាកចេញទំនងជាមិនអាចទៅរួចឡើយ។ ស្ត្រីដែលរងគ្រោះ ៖

- អាចនឹងគ្មានកន្លែងមានសុវត្ថិភាពសម្រាប់ទៅ។
- អាចនឹងគ្មានមធ្យោបាយសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងកូនៗ ក្រៅតែពីប្តីដែលប្រើហិង្សានោះ។
- អាចនឹងភ័យខ្លាចខ្លាំងក្នុងការទទួលយកការគាំទ្រណាមួយដែលអាចនឹងមានសម្រាប់ពួកគេ និងកូនៗពួកគេ។
- អាចនឹងត្រូវបានអ្នកប្រើអំពើហិង្សាលើពួកនាង បញ្ចុះបញ្ចូលឲ្យនាងមានអារម្មណ៍ថាពួកគេមិនសមទទួលបានជំនួយអ្វីឡើយ។

ដូច្នេះ មូលហេតុមួយក្នុងចំណោមមូលហេតុនៃអំពើហិង្សាផ្នែកយេនឌ័រ គឺកង្វះឱកាសសម្រាប់ស្ត្រី។ តាមរយៈការបង្កើតនូវជម្រើសផ្សេងៗសម្រាប់ស្ត្រីប្រើប្រាស់នៅក្នុងស្ថានភាពខាងលើ សហគមន៍របស់អ្នកអាចបង្ការមិនឲ្យស្ត្រីជាប់ផុងខ្លួនក្នុងទំនាក់ទំនងប្រកបដោយហិង្សា និងវដ្តហិង្សាបាន។



*នៅពេលខ្លះ ភាពភ័យខ្លាចនិងទុក្ខវេទនាមានពាសពេញក្នុងក្បាលរបស់យើង រហូតដល់យើងចាំបាច់ត្រូវជំរុញឲ្យសិក្សាស្វែងរក "មូលហេតុ" និងព្យាយាមស្វែងយល់។*

Sharon Ishcomer-Fleming,
Choctaw Nation, US

## សកម្មភាព — ស្វែងយល់ពីមូលហេតុនៃអំពើហិង្សាផ្ទែកយេនឌ័រ

1. ក្រោយពេលធ្វើសកម្មភាពនៅក្នុងទំព័រ 148 រួច ចូរស្នើឲ្យអ្នកសំដែងទុកដាក់គ្រឿងតែងឆាក និងសម្លៀកបំពាក់សំដែងមួយកន្លែង រួចមកចូលរួមជាមួយក្រុមវិញ។ ការស្នើឲ្យអ្នកសំដែងដកចេញនូវតួនាទីក្នុងការសំដែងរបស់ពួកគេមុននឹងមកចូលរួមពិភាក្សាវិញ ជួយបញ្ចៀសការចាត់ទុកអ្នកចូលរួមជាអ្នកប្រើហិង្សា ឬជនរងគ្រោះ។ ជាការសំខាន់ណាស់ដែលមិនត្រូវធ្វើឲ្យបុគ្គលណាម្នាក់ភាន់ច្រឡំជាមួយនឹងតួនាទីដែលគាត់ឬនាងបានសំដែងរួចនោះឡើយ។

2. ពិភាក្សាពីសាច់រឿងនីមួយ។ សួរសំណួរដែលនាំឲ្យក្រុមទាំងមូលប្រាប់ពីអ្វីដែលបានកើតឡើងនិងបានជំរុញឲ្យបុរសនោះប្រើហិង្សា។ ខណៈដែលពួកគេប្រាប់មូលហេតុផ្សេងៗដែលឈានទៅដល់ការប្រើហិង្សា អ្នកអាចនឹងចង់សរសេរមូលហេតុទាំងនោះនៅលើផ្ទាំងក្រដាសឬក្តារខៀន។

3. វិភាគមូលហេតុនៃអំពើហិង្សាទាំងនោះ។ ជួយក្រុមធ្វើការសម្រេចចិត្តថាតើមូលហេតុណាខ្លះដែលពួកគេឲ្យឈ្មោះថា "កត្តាជំរុញ" ឲ្យមានការប្រើហិង្សា និងមូលហេតុណាខ្លះដែលជា "មូលហេតុឫសគល់" ។ លំហាត់ "ប៉ុន្តែហេតុអ្វី?" អាចជួយឲ្យក្រុមមើលឃើញភាពខុសគ្នារវាង "កត្តាជំរុញ" និង "មូលហេតុឫសគល់។ ការមើលឃើញមូលហេតុឫសគល់ជួយឲ្យងាយយល់ពីរបៀបដែលការរំពឹងទុកក្នុងយេនឌ័រនាំឲ្យកើតមានហិង្សា។

*សំណួរ៖ ហេតុអ្វីបានជាបុរសនោះខឹង?*

*ចម្លើយ៖ ពីព្រោះប្រពន្ធគាត់ទៅចូលរួមប្រជុំ ហើយភ្លេចចម្អិនអាហារពេលល្ងាចទុកជូនគាត់។*

*សំណួរ៖ ប៉ុន្តែ ហេតុអ្វីរឿងនឹងធ្វើឲ្យគាត់ខឹងខ្លាំងម្ល៉េះ?*

*ចម្លើយ៖ ពីព្រោះគាត់រំពឹងថាប្រពន្ធគាត់នៅផ្ទះនិងចម្អិនអាហារពេលល្ងាចសម្រាប់គាត់រៀងរាល់យប់។*

*សំណួរ៖ ប៉ុន្តែ ហេតុអ្វីបានជាគាត់រំពឹងដូច្នោះ?*

*ចម្លើយ៖ ពីព្រោះគាត់គិតថាតួនាទីប្រពន្ធគឺគោរពគាត់ មិនមែនទៅចូលរួមប្រជុំនោះទេ។*

*សំណួរ៖ ប៉ុន្តែ ហេតុអ្វីបានជាគាត់គិតដូច្នោះ?*

*ចម្លើយ៖ ពីព្រោះបុរសនិងស្ត្រីត្រូវបានបង្រៀនឲ្យជឿថា វាជាការងាររបស់ស្ត្រីដែលត្រូវគោរពប្តី។*



## សកម្មភាព ស្វែងយល់ពីមូលហេតុនៃអំពើហិង្សាផ្អែកយេនឌ័រ (ត)

4 ស្វែងយល់ពីទំនាក់ទំនងរវាងអំពើហិង្សានៅក្នុងការសំដែងរឿង និងគំនិតអំពីរបៀបដែលបុរសនិងស្ត្រីគួរតែធ្វើសកម្មភាពនិងគិត។ ជាឧទាហរណ៍៖ ហេតុអ្វីបានជាបុរសនៅក្នុងការសំដែងតួនេះជឿថា វាជារឿងធម្មតាទេដែលត្រូវប្រើហិង្សាលើស្ត្រី (និងប្រហែលជាអ្នកដទៃទៀតផង)? ហេតុអ្វីបានជាមនុស្សយ៉ាងច្រើនអត់ឱនចំពោះអំពើហិង្សាលើស្ត្រី? តើជំនឿអ្វីខ្លះអំពីយេនឌ័រ ដែលបង្រៀនបុរសនិងស្ត្រីឲ្យគិតថា ការប្រើហិង្សាលើស្ត្រីគឺជារឿងធម្មតា?

5 អ្នកអាចនឹងសន្និដ្ឋានដោយសួរថា តើនឹងមានរឿងអ្វីកើតឡើងនៅក្នុងស្ថានភាពនីមួយៗនោះ ប្រសិនបើមិនប្រើប្រាស់អំពើហិង្សា។ តើគាត់នឹងធ្វើអ្វីជំនួសមកវិញ? ឬអ្នកអាចបន្តជាមួយសកម្មភាពបន្ទាប់ដើម្បីជួយក្រុមគិតអំពីមធ្យោបាយបញ្ឈប់អំពើហិង្សាផ្អែកយេនឌ័រ។

## សកម្មភាព ការសំដែង "ការបញ្ចប់រឿងដោយភាពរីករាយ" ដើម្បីគិតអំពីការផ្លាស់ប្ដូរ

1 ស្នើឲ្យក្រុមដែលបានសំដែងតួក្នុងស្ថានភាពនីមួយៗនោះ ជួបគ្នាដាច់ដោយឡែកម្ដងទៀតរយៈពេល ១៥នាទី និងពិភាក្សាពីរបៀបដែលតួអង្គនីមួយៗអាចធ្វើសកម្មភាពខុសពីមុន ដើម្បីកុំឲ្យស្ថានភាពនោះបញ្ចប់ទៅដោយហិង្សា។ ជំរុញឲ្យគ្រប់គ្នាគិតអំពីសកម្មភាពផ្សេងៗដែលជនរងគ្រោះ អ្នកប្រើហិង្សា និងសាក្សីអាចអនុវត្ត។ ស្នើឲ្យពួកគេកុំដាក់ការទទួលខុសត្រូវទាំងអស់ទៅលើស្ត្រី!

2 សំដែងតួក្នុងស្ថានភាពនីមួយៗម្ដងទៀត ដោយម្ដងនេះត្រូវផ្លាស់ប្ដូរនូវអ្វីដែលកើតឡើង ដើម្បីឲ្យសាច់រឿងបញ្ចប់ទៅដោយគ្មានអំពើហិង្សា។ ការមើលឃើញពីជម្រើសណាមួយចំពោះអំពើហិង្សា អាចផ្ដល់នូវកម្លាំងដ៏ខ្លាំងក្លាជាពិសេសសម្រាប់អ្នកដែលធ្លាប់រងគ្រោះពីអំពើហិង្សា។

3 នៅក្នុងការសំដែងតួ "ការបញ្ចប់រឿងដោយភាពរីករាយ" តើអ្នកគិតថាអ្វីទៅដែលបានជួយឲ្យអ្នកចូលរួម និងអ្នកឃើញហេតុការណ៍ ធ្វើអ្វីមួយខុសពីនេះ? តើអ្នកគិតថាពួកគេអាចនឹងទទួលបានគំនិតធ្វើសកម្មភាពនេះពីប្រភពណា ឬចំណុចខ្លាំងពីណា?

4 ពិភាក្សាពីគំនិតដើម្បីផ្លាស់ប្ដូរមូលហេតុឫសគល់មួយចំនួនដែលនាំឲ្យមានអំពើហិង្សាផ្អែកយេនឌ័រ។ ស្នើឲ្យក្រុមពិចារណាពីវិធីដែលអាចជួយឲ្យគ្រួសារនិងអ្នកដទៃក្នុងសហគមន៍ មើលឃើញបញ្ហា និងគ្រោះថ្នាក់នៃបញ្ហា។ អ្នកអាចនឹងស្នើឲ្យពួកគេត្រិះរិះអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ។ តើមានអ្វីមួយដែលពួកគេចង់ផ្លាស់ប្ដូរនៅក្នុងទំនាក់ទំនងរបស់ពួកគេដែរឬទេ? តើពួកគេអាចបញ្ចូលកុមារក្នុងការបង្កើតឲ្យមានការផ្លាស់ប្ដូរនាពេលអនាគតដែរឬទេ?

ផ្អែកលើចម្លើយចំពោះសំណួរទាំងនេះ ក្រុមអាចត្រៀមលក្ខណៈរួចរាល់ដើម្បីរៀបចំសកម្មភាពជាក់លាក់មួយចំនួន។ (សូមមើលចំណុច "បង្កើតផែនការសកម្មភាព" ទំព័រ 26)។

# អំណាច និងអំពើហិង្សា

ជារឿយៗ អ្នកមានឋានៈខ្ពស់ និងមានអំណាចខ្លាំង ចូលចិត្តប្រើអំពើហិង្សាលើអ្នកមានឋានៈទាប ឬអំណាចតិច។ នេះអាចជាទីកន្លែងចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ពិភាក្សាជាមួយបុរសពីអំពើហិង្សាផ្នែកយេនឌ័រ។ វាអាចនឹងងាយស្រួលជាងសម្រាប់បុរសក្នុងការស្វែងយល់ពីគ្រោះថ្នាក់ និងភាពអយុត្តិធម៌ដែលស្ត្រីបានទទួលរង ប្រសិនបើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទិននឹងភាពគ្មានអំណាច និងហិង្សាត្រូវបានទទួលស្គាល់ផងដែរនោះ។

ដើម្បីត្រៀមលក្ខណៈអនុវត្តសកម្មភាព២បន្ទាប់ អ្នកអាចនឹងចង់អានអំពីយេនឌ័រ អំណាច និងសុខភាព (ទំព័រ 52 ដល់ 53)។

**សកម្មភាព** | **អំណាចខ្លាំង និង អំណាចតិច**

1. បង្កើតតារាងធំមួយមាន២កូឡោន។ ក្នុងនោះកូឡោនមួយដាក់ចំណងជើងថា "អំណាចខ្លាំង" និងកូឡោនមួយទៀត "អំណាចតិច។
2. ស្នើឲ្យអ្នកចូលរួមបំផុសគំនិតអំពីក្រុមមនុស្សនៅក្នុងសហគមន៍ដែលមានអំណាចខ្លាំងបំផុត។ សរសេរគំនិតរបស់ពួកគេមួយបញ្ជីនៃផ្នែកអំណាចខ្លាំងក្នុងតារាង។ ចូរប្រាកដថា អ្នកចូលរួមផ្តោតសំខាន់លើឋានៈ និងអំណាចសង្គម មិនមែនភាពខ្លាំងផ្នែកកម្លាំងកាយនោះទេ។
3. បន្ទាប់មកសួរថា តើក្រុមមានអំណាចទាំងនេះ មានអំណាចទៅលើក្រុមណាខ្លះ។ ដាក់ក្រុមទាំងនេះទៅក្នុងកូឡោនមួយទៀតសម្រាប់អ្នកមានអំណាចតិច។
4. សួរថា តើមានក្រុមណាផ្សេងទៀតដែលមានអំណាចតិច ហើយបញ្ចូលពួកគេទៅក្នុងកូឡោនមានអំណាចតិច។ បន្ទាប់មក ចូរសម្រេចចិត្តថាតើនរណាមានអំណាចខ្លាំងជាងក្រុមចុងក្រោយទាំងនេះ និងបន្ថែមក្រុមទាំងនោះទៅក្នុងកូឡោនអំណាចខ្លាំង។

| អំណាចខ្លាំង | អំណាចតិច |
|---|---|
| បុរស | ស្ត្រី |
| មនុស្សធំ | កុមារឬយុវជន |
| អ្នកមាន | អ្នកក្រ |
| ស្បែកស | ស្បែកខ្មៅ |
| ចៅហ្វាយ | កម្មករ |
| ជនជាតិភាគច្រើន | ជនជាតិភាគតិច |
| ទីក្រុង | ជនបទ |
| ជនជាតិដើម | ជនអន្តោប្រវេសន៍ |
| រៀបការ | នៅលីវ លែងលះ |
| មានការអប់រំ | គ្មានការអប់រំ |
| គ្មានពិការភាព | មានពិការភាព |
| គ្មានឬមិនបានធ្វើតេស្តមេរោគអេដស៍ | មានមេរោគអេដស៍ |
| ភេទធម្មតា | ភេទទីបី |


www.hesperian.org health guides

## សកម្មភាព អំណាចខ្លាំង និង អំណាចតិច (ត)




5 និយាយពីអ្វីដែលតារាងនេះបង្ហាញ។ ចូរបញ្ជាក់ថា មនុស្សនៅក្នុងក្រុមមានអំណាចខ្លាំងគឺមានបុព្វសិទ្ធិឬគុណសម្បត្តិដែលមនុស្សនៅក្នុងក្រុមមានអំណាចតិចមិនមាននោះទេ។ ពិភាក្សាពីប្រភេទបុព្វសិទ្ធិផ្សេងៗគ្នាដែលមានចំពោះអ្នកដែលមានស្ថានភាពសេដ្ឋកិច្ច ការអប់រំ និងឋានៈសង្គមខ្ពស់ជាង។ អ្នកក៏អាចនឹងពិភាក្សាពីប្រភេទផ្សេងៗនៃអំពើហិង្សាដែលមនុស្សនៅក្នុងក្រុមមានអំណាចច្រើនប្រើប្រាស់ទៅលើមនុស្សនៅក្នុងក្រុមមានអំណាចតិចផងដែរ។

6 ស្នើឲ្យអ្នកចូលរួមនិយាយអំពីរបៀបដែលពួកគេស័ក្តិសមស្ថិតក្នុងក្រុមមានអំណាចច្រើន ឬក្រុមមានអំណាចតិច និងបុព្វសិទ្ធិឬគុណសម្បត្តិដែលពួកគេទទួលបាន។ ពិភាក្សាពីអ្វីដែលមនុស្សនៅក្នុងក្រុមទាំងពីរផ្នែកនៃតារាងអាចធ្វើដើម្បីធ្វើឲ្យឋានៈនិងអំណាចរវាងក្រុមផ្សេងៗកាន់តែមានសមភាពរវាងគ្នា។ (សកម្មភាពបន្ទាប់អាចជួយមនុស្សនៅក្នុងក្រុមនោះមើលឃើញពីទីកន្លែងដែលស័ក្តិសមសម្រាប់ពួកគេធៀបនឹងមនុស្សក្នុងក្រុមផ្សេង)។



**សកម្មភាព** ## ការចលនាឱ្យមានតុល្យភាពអំណាច

មធ្យោបាយមួយផ្សេងទៀតដើម្បីស្វែងយល់ពីអំណាចនិងបុព្វសិទ្ធិ ជាពិសេសនៅក្នុងក្រុមដែលមានសមាសភាពចម្រុះ គឺស្នើឲ្យអ្នកចូលរួមបម្លាស់ទីនៅក្នុងបន្ទប់ ដោយផ្អែកលើប្រភេទអំណាចដែលពួកគេមាន ឬមិនមាន។ ចូរចងចាំថា សកម្មភាពនេះអាចនឹងធ្វើឲ្យអ្នកចូលរួមមានអារម្មណ៍មិនស្រួល ឬបង្កឲ្យមានអារម្មណ៍ខ្លាំងក្លា។ សកម្មភាពនេះអាចឲ្យអនុវត្តជាផ្នែកមួយនៃជំហានទី៦ នៅទំព័រ 155 ។

1. ប្រើប្រាស់តារាង "អំណាចខ្លាំង" និង "អំណាចតិច" ពីសកម្មភាពមុន ឬរៀបចំបញ្ជីប្រហាក់ប្រហែលមុននឹងអនុវត្តជំហានបន្ទាប់នៅទីនេះ។

2. ឲ្យគ្រប់គ្នាឈរជាជួរនៅផ្នែកម្ខាងនៃកន្លែងប្រជុំ។

3. និយាយថា "បោះមួយជំហានទៅមុខប្រសិនបើអ្នកគ្មានពិការភាពទេ" ឬប្រាប់ឈ្មោះក្រុមមួយផ្សេងទៀតដែលមានអំណាចខ្លាំងជាង។ បន្ទាប់មកនិយាយថា "បោះមួយជំហានទៅមុខ" ម្តងទៀត និងប្រាប់ឈ្មោះក្រុមមួយផ្សេងទៀតដែលមានអំណាចខ្លាំងជាង។ សម្រាប់ក្រុមដែលមានអំណាចតិច ចូរនិយាយថា "បោះមួយជំហានថយក្រោយប្រសិនបើអ្នកមានអាយុក្រោម២៥ឆ្នាំ។ ក្រោយពីបានបោះជំហានបានច្រើនហើយ ពួកគេអាចនឹងមានភាពភ្ញាក់ផ្អើលនៅពេលមើលឃើញកន្លែងដែលពួកគេកំពុងឈរ។




4. ជាចុងក្រោយ អ្នកអាចចាប់ផ្តើមការពិភាក្សាដោយប្រើប្រាស់សំណួរដែលមាននៅក្នុងជំហានទី៥ នៃសកម្មភាពក្នុងទំព័រមុន។

# បុរសអាចជួយបញ្ឈប់អំពើហិង្សា

ស្ត្រីតែម្នាក់ឯងមិនអាចបញ្ឈប់អំពើហិង្សាមកលើពួកគេបាននោះទេ។ មិនថាមានស្ត្រីដែលចាកចេញពីទំនាក់ទំនងហិង្សា គាំទ្រគ្នាទៅវិញទៅមក ឬព្យាយាមកែប្រែច្បាប់ច្រើនយ៉ាងណាក៏ដោយ ក៏អំពើហិង្សាផ្នែកយេនឌ័រនឹងអាចបញ្ឈប់បានតែនៅពេលណាដែលបុរសប្រឆាំងនឹងវា និងជួយគ្នាផ្លាស់ប្តូរប៉ុណ្ណោះ។ បុរសចេះបង្រៀនក្មេងប្រុសពីរបៀប "ក្លាយជាបុរស" បានប្រសើរជាងស្ត្រី។ ឪពុកបង្ហាញកូនប្រុសពីរបៀបប្រព្រឹត្តចំពោះស្ត្រីនិងក្មេងស្រី។ ជាធម្មតា អ្នកដែលមានអំណាចនិងឥទ្ធិពល ដូចជាចៅក្រមអ្នកនយោបាយ មន្ត្រីនគរបាល វេជ្ជបណ្ឌិត ច្រើនតែជាបុរស។ នៅពេលដែលពួកគេក្លាយជាសម្ពន្ធមិត្ត យើងពិតជាអាចផ្លាស់ប្តូរវិធីដែលបុរសត្រូវបានរំពឹងថាធ្វើសកម្មភាព និងបង្កើតច្បាប់និងគោលនយោបាយដែលការពារនិងគាំទ្រស្ត្រី។

ជាការពិត បុរសភាគច្រើនមិនឯកភាពជាមួយឥរិយាបថនិងជំនឿដែលគាំទ្រអំពើហិង្សាផ្នែកយេនឌ័រនោះទេ ប៉ុន្តែមានបុរសជាច្រើនបានប្រឹងប្រែងតិចតួចដើម្បីជំទាស់ឬបញ្ឈប់វា។ បុរសមួយចំនួនមិនប្រើប្រាស់អំពើហិង្សានៅក្នុងទំនាក់ទំនងរបស់ពួកគេនោះទេ ហើយបុរសផ្សេងទៀតកំពុងធ្វើការដើម្បីបង្ការហិង្សា ប៉ុន្តែខ្វះការគាំទ្រ។ មានបុរសជាច្រើនទៀតទំនងជាបានចូលរួមតែមិនដឹងពីរបៀបរបប។ ពេលខ្លះ បុរសគឺជាអ្នករស់រានពីអំពើហិង្សា ប៉ុន្តែដូចស្ត្រីផងដែរ បុរសតិចតួចបានទទួលការគាំទ្រដើម្បីជាសះស្បើយពីបទពិសោធន៍ល្វីងជូរចត់របស់ពួកគេ។

## បទពិសោធន៍ពីគម្រោងបុរសនៃក្រុងអូកលែន

នៅពេលដែលលោក ផូល ឃីវែល (Paul Kivel) ប្រាប់រឿងរ៉ាវអំពីគម្រោងបុរសនៃក្រុងអូកលែន (Oakland Men's Project) គាត់តែងតែសរសើរការជំរុញទឹកចិត្តរបស់ពួកគេចំពោះកិច្ចខិតខំរបស់ស្ត្រីក្នុងការលើកកម្ពស់ការយល់ដឹងអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ។ លោកផូល ពណ៌នាអំពីបច្ចេកទេសដែលពួកគេបានសម្រួលពីក្រុមស្ត្រីដូចខាងក្រោម ៖

ជាដំបូង យើងបង្កើតការបង្ហាញ "ជារូបភាពនិងបាឋកថា" ដោយប្រើប្រាស់រូបភាពពីទស្សនាវដ្ដីផ្លូវភេទ គម្របកាសែត សារផ្សាយពាណិជ្ជកម្មក្នុងទស្សនាវដ្ដី និងសៀវភៅរឿងកំប្លែង។ រូបភាពភាគច្រើនបានបង្ហាញពីស្ត្រីដែលកំពុងរងគ្រោះពីអំពើបន្ទះបង្អាប់ វាយដំ ឬរំលោភសេពសន្ថវៈ។ យើងចង់ឲ្យបុរសមានអារម្មណ៍ភ្ញាក់ផ្អើល និងខឹងសម្បាចំពោះអំពើហិង្សាក្នុងរូបភាពទាំងនោះ។ បុរសខ្លះភ្ញាក់ផ្អើល ខ្លះទៀតមិនភ្ញាក់ផ្អើលអ្វីទេ។ ការបង្ហាញនោះកម្រនឹងញ៉ាំងឲ្យបុរសធ្វើសកម្មភាពដើម្បីបញ្ចប់ហិង្សាណាស់។ ហើយវាមិនបានជួយឲ្យបុរសយល់ដឹងពីរបៀបដំណើរការនៃប្រព័ន្ធអំពើហិង្សាប្រព្រឹត្តដោយបុរស ឬរបៀបដែលវាអាចនឹងបង្កផលប៉ះពាល់ចំពោះពួកគេដោយផ្ទាល់នោះទេ។



យើងក៏ឃើញមានការខឹងសម្បាពីបុរស ខណៈដែលយើងបាននិយាយចេញផងដែរ។ បុរសមួយចំនួនមានអារម្មណ៍ថាទទួលរងការស្តីបន្ទោសដោយអយុត្តិធម៌។ យើងបានប្រាប់បុរសថា ពួកគេមានអំណាចនិងមានឫទ្ធិសិទ្ធិ និងថាអំពើហិង្សាគឺជាការទទួលខុសត្រូវរបស់ពួកគេ។ បុរសដែលយើងបាននិយាយជាមួយ បានប្រាប់យើងថា ជាការពិត ពួកគេមានអារម្មណ៍ខឹងសម្បា ឈឺចាប់ រងគ្រោះ និងគ្មានអំណាច។

បន្ទាប់មក យើងបានរៀបចំសិក្ខាសាលាជាមួយក្មេងប្រុសអាយុ ១៣ និង១៤ឆ្នាំ ដើម្បីជួយពួកគេឲ្យមើលឃើញថាបុរសជាមនុស្សខ្លាំង និងមានអំណាចនៅក្នុងពិភពលោក ហើយស្ត្រីមិនមានទេ។ ក្មេងប្រុសទាំងនោះនិយាយថា ពួកគេកំពុងព្យាយាមដើម្បីក្លាយខ្លួនជាអ្នកមានអំណាច ប៉ុន្តែពួកគេមិនមានទេ។ ជាទីបញ្ចប់ យើងទទួលសារភាពថា ក្មេងប្រុសមិនមានអំណាចនៅក្នុងសង្គមយើងទេ។ ជារឿយៗ ពួកគេជាជនរងគ្រោះ និងជាអ្នករួចរស់រានពីអំពើហិង្សានៅក្នុងគ្រួសារ សហគមន៍ និងស្ថាប័ន។ យើងបានមើលឃើញថា ទាំងក្មេងប្រុសនិងក្មេងស្រី សុទ្ធតែរងគ្រោះពីអំពើហិង្សា ដែលភាគច្រើនគឺប្រព្រឹត្តឡើងដោយបុរស។ ជារឿយៗ ក្មេងប្រុសត្រូវបានគេបង្រៀនឲ្យប្រព្រឹត្តហិង្សាលើអ្នកដទៃ។ ក្មេងស្រីត្រូវបានបង្រៀនឲ្យរំពឹងទុកថា ខ្លួននឹងក្លាយជាជនរងគ្រោះនៃអំពើហិង្សារបស់បុរសអស់មួយជីវិត។

យើងបានស្វែងយល់ថា បុរសអាចផ្លាស់ប្តូរនៅពេលដែលពួកគេយល់ដឹងពីរបៀបដែលយើងត្រូវបានចិញ្ចឹមឲ្យក្លាយជាបុរស និងការឈឺចាប់ដែលយើងបានទទួលនៅក្នុងដំណើរការនោះ។ នេះសំដៅដល់ការយល់ដឹងពីទំនាក់ទំនងរវាងការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ និងរបៀបដែលយើងជាបុរសបានរងឥទ្ធិពលពីការរំពឹងទុកអំពីភាពជាបុរស។

## តើបុរសអាចខ្លាំងដោយគ្មានហិង្សាយ៉ាងដូចម្ដេចទៅ?

ក្រុមគាំទ្រមួយដែលជួបប្រជុំជាប្រចាំ អាចជួយបុរសឲ្យពិភាក្សា ថាតើពួកគេចង់ក្លាយជាបុរស មិត្តប្រុស ប្ដី និងឪពុកប្រភេទណា រួមទាំងការរៀនសូត្រពីរបៀបបដិសេធនិងចៀសវាងអំពើហិង្សាផងដែរ។

ក្រុមបុរសមួយឈ្មោះ Diversidades ដែលមានមូលដ្ឋាននៅទីក្រុងអូហ្សាកា ប្រទេសម៉ិកស៊ិក ប្រើប្រាស់សំណួរខាងក្រោមដើម្បីពិភាក្សា ៖

- តើអំពើហិង្សាប៉ះពាល់ដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេចខ្លះ? តើអ្នកជួបប្រទះអំពើហិង្សាបែបណា កាលនៅជាក្មេងប្រុស និងកាលនៅជាក្មេងជំទង់?
- តើអ្នកប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារនិងក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នកតាមរបៀបណាខ្លះ? តើជាប្រភេទអំពើហិង្សាអ្វីខ្លះ? សួរខ្លួនឯងថា ហេតុអ្វីបានជាអ្នកប្រើហិង្សា? តើមានជម្រើសផ្សេងដែរឬទេ?
- តើអំពើហិង្សា ប៉ះពាល់ទំនាក់ទំនងរបស់អ្នក ជាមួយដៃគូរបស់អ្នក ឬជាមួយកូនៗរបស់អ្នកយ៉ាងដូចម្ដេច? តើអ្វីៗនឹងអាចប្រសើរឡើងដោយរបៀបណាប្រសិនជាគ្មានអំពើហិង្សា?
- តើក្មេងប្រុសនិងបុរសមានឥទ្ធិពលចំពោះគ្នារបៀបណាក្នុងការប្រើប្រាស់ឬចៀសវាងអំពើហិង្សា? តើអ្នកអាចមានឥទ្ធិពលបែបណា ទៅលើបុរសនិងក្មេងប្រុសដទៃទៀត ដើម្បីបញ្ចៀសអំពើហិង្សា?

## ការជួយក្មេងប្រុសឱ្យសួរសំណួរអំពីអំពើហិង្សាផ្នែកយេនឌ័រ

ក្មេងប្រុសជំទង់កំពុងសកម្មក្នុងការបង្កើតគំនិតរបស់ពួកគេអំពីការក្លាយខ្លួនជាបុរស ដូច្នេះវាអាចជាពេលវេលាដ៏សំខាន់មួយដើម្បីចាក់គ្រឹះក្នុងការបង្កើតទំនាក់ទំនងប្រកបដោយសុខភាពល្អជាមួយក្មេងស្រីនិងស្ត្រី។ ខាងក្រោមនេះជារឿងរ៉ាវរបស់គម្រោងមួយដែលបានធ្វើការជាមួយក្មេងប្រុសជំទង់ជាក្រុមតូចៗក្នុងរយៈពេលពេញមួយឆ្នាំ ហើយពេលខ្លះអូសបន្លាយពេលយូរជាងនេះ។ គម្រោងនេះមានគោលដៅជំរុញឲ្យក្មេងប្រុសធ្វើការវិភាគលើពិភពជុំវិញខ្លួន និងបង្កើតទស្សនៈផ្ទាល់ខ្លួនអំពីតួនាទីយេនឌ័រ។

### ការត្រិះរិះ ជួយឱ្យក្មេងប្រុសចោទសួរអំពីភាពអយុត្តិធម៌ក្នុងយេនឌ័រ

នៅចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១០ កម្មវិធីបណ្ដុះមនសិការក្មេងប្រុសជំទង់ (CMA) បានបណ្ដុះបណ្ដាលក្មេងប្រុសជាង ២០០០នាក់នៅក្នុងប្រទេសនីហ្សេរីយ៉ា ដើម្បីពិចារណាពីឫសគល់នៃវិសមភាពយេនឌ័រ និងគ្រោះថ្នាក់ដែលវាបង្កឡើង។ ការយកចិត្តទុកដាក់ ផ្ដោតសំខាន់លើអំពើហិង្សាលើស្ត្រី ពីព្រោះវាជារឿងកើតឡើងទូទៅនៅក្នុងសង្គមនីហ្សេរីយ៉ា។

វិធីសាស្ត្រសំណួរ-ចម្លើយរបស់កម្មវិធី CMA បានជួយឲ្យក្មេងប្រុសទាំងនោះ អភិវឌ្ឍជំនាញទំនាក់ទំនង និងត្រិះរិះ។ ខាងក្រោមនេះជាឧទាហរណ៍មួយបង្ហាញពីការពិភាក្សាជាក្រុមអំពីអំពើរំលោភសេពសន្ថវៈ។

អ្នកដឹកនាំការពិភាក្សា ចាប់ផ្ដើមដោយសួរទៅកាន់ក្មេងប្រុសថា តើមិត្តស្រីរបស់ពួកគេនិយាយអ្វីនៅក្នុងអំឡុងពេលរ៉ូមែនទិក។ ក្មេងប្រុសលើកដៃឆ្លើយ៖




ភ្លាមនោះក្មេងប្រុសក៏ទទួលស្គាល់ថា ក្មេងស្រីចង់មានន័យថាទេ នៅពេលដែលពួកគេនិយាយពាក្យថាទេ។

សកម្មភាពបន្ទាប់ អាចប្រើប្រាស់ជាមួយក្រុមណាមួយក៏បាន ប៉ុន្តែវាអាចជួយដល់បុរសជាពិសេស ឲ្យគិតអំពីវិធីជំទាស់យ៉ាងសកម្មទៅនឹងអំពើហិង្សាផ្អែកយេនឌ័រ និងបង្ការវានៅក្នុងស្ថានភាពជីវិតជាក់ស្តែង។ នៅក្នុងសកម្មភាពនេះ អ្នកចូលរួមនឹងស្រមៃថា កំពុងប្រទះឃើញបុរសម្នាក់ប្រើអំពើហិង្សាលើស្ត្រី ឬមានវត្តមាននៅក្នុងពេលដែលអាចកើតមានអំពើហិង្សា ឬអំពើរំលោភសេពសន្ថវៈ។ បន្ទាប់មក ពួកគេត្រូវបានស្នើឲ្យគិតគូរអំពីវិធីដែលពួកគេអាចនឹងប្រើប្រាស់ដើម្បីធ្វើអន្តរាគមន៍នៅមុន ក្នុងអំឡុងពេល និងក្រោយពេលកើតមានអំពើហិង្សានោះ តាមរយៈការប្រឈមមុខជាមួយនឹងបុរសនោះ ឬក៏ជួយស្ត្រីរងគ្រោះ។

## សកម្មភាព — ការសំដែងតួជាអ្នកឃើញហេតុការណ៍

1. ដើម្បីរៀបចំត្រៀមលក្ខណៈ៖ ចូរបំផុសគំនិតបង្កើតតារាងមួយ រាយឈ្មោះស្ថានភាពដែលមនុស្សអាចនឹងប្រទះឃើញ។ អ្នកអាចប្រើប្រាស់ស្ថានភាពដូចជាស្ថានភាពក្នុងការរៀបចំសំដែងតួ (ទំព័រ 146) និងបន្ថែមចំណុចដូចខាងក្រោម ៖
   - នៅខាងក្រៅពិធីជប់លៀងមួយ អ្នកបានឃើញក្មេងស្រីម្នាក់កំពុងស្រវឹងស្រា។ ក្មេងប្រុសម្នាក់កំពុងជំរុញឲ្យនាងទៅជាមួយគាត់ ប៉ុន្តែនាងហាក់ដូចជាមិនប្រាកដក្នុងចិត្តទេ។
   - ក្មេងស្រីម្នាក់កំពុងដើរតាមដងផ្លូវងងឹតតែម្នាក់ឯង។ ក្មេងប្រុសមួយក្រុមក៏បានហៅ ហួច និងស្រែកពាក្យអសុរសដាក់នាង និងចាប់ផ្តើមដើរតាមពីក្រោយនាង។
   - អ្នកឮមិត្តភ័ក្តិម្នាក់និយាយកំប្លែងអំពីការរំលោភសេពសន្ថវៈ។
2. ឲ្យអ្នកចូលរួម ចាប់ដៃគូ រួចផ្តល់ស្ថានភាពមួយទៅដល់គូនីមួយ។ សួរពួកគេថាតើនឹងមានរឿងអ្វីអាចកើតឡើង រួចឲ្យពួកគេបង្កើតបញ្ជីមួយដែលមានវិធីយ៉ាងតិច៤ ដែលពួកគេអាចនឹងប្រើសម្រាប់ប្រតិកម្មតប។ ចូរលើកជាយោបល់ថាពួកគេគួរគិតគូរអំពីសកម្មភាព ឬវិធីដែលពួកគេអាចប្រើ ដើម្បីនិយាយជាមួយបុរស ឬស្ត្រីរូបនោះដើម្បីបង្ការ ឬបញ្ឈប់អំពើហិង្សា។ លើកជាយោបល់ផងដែរថា ពួកគេគួរស្រមៃថាតើពួកគេអាចនឹងធ្វើអ្វីនៅមុន នៅក្នុងអំឡុង និងនៅក្រោយពេលព្រឹត្តិការណ៍កន្លងផុតទៅ។ តើអ្វីទាំងអស់នោះអាចធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងដូចម្តេច?
3. ស្នើឲ្យដៃគូនីមួយៗចែករំលែកនូវស្ថានភាពរបស់ក្រុមពួកគេ និងបញ្ជីសកម្មភាពរបស់ពួកគេ ដោយពន្យល់ថាតើប្រតិកម្មមួយណាដែលនឹងមានភាពជាក់លាក់បំផុតសម្រាប់ពួកគេ ហើយពន្យល់ពីហេតុផលផងដែរ។ ជួយឲ្យពួកគេមានអារម្មណ៍បើកទូលាយក្នុងការចែករំលែកនូវអ្វីដែលពិបាកបំផុតសម្រាប់ពួកគេអនុវត្ត និងប្រាប់ហេតុផលផង។
4. ផ្តល់ឱកាសឲ្យក្រុមទាំងមូលពិភាក្សាពីគំនិតផ្សេងៗ និងសម្រេចថាតើការឆ្លើយតបមួយណាដែលអាចផ្តល់ភាពជោគជ័យធំបំផុតក្នុងការបញ្ឈប់អំពើហិង្សា។

អ្នកអាចបញ្ចប់សកម្មភាពនេះដោយការពិចារណាជាមួយក្រុម អំពីគំនិតដែលបង្កភាពងាយស្រួលដល់មិត្តភក្តិ អ្នកជិតខាង និងអ្នកឃើញហេតុការណ៍ ក្នុងការធ្វើសកម្មភាពបង្ការ ឬបញ្ឈប់អំពើហិង្សាដែលពួកគេជួបប្រទះ។



*ជាពិសេសនៅពេលកំពុងធ្វើការជាមួយក្រុមបុរសនិង ស្ត្រីរួមគ្នា ចូរកុំព្យាយាមស្តីបន្ទោសតែលើបុរស។ យើងត្រូវស្វែងរកវិធីប្រកបដោយការស្រឡាញ់និងការទទួលយកបុរស ខណៈដែលបដិសេធ និងជំទាស់អំពើហិង្សាដែលបុរសប្រព្រឹត្ត។ ជួយឲ្យបុរសមើលឃើញថា ការបញ្ឈប់អំពើហិង្សាលើ ស្ត្រី ផ្តល់ផលប្រយោជន៍ដល់គ្រប់គ្នា។*

## យុទ្ធនាការបូពណ៌ស

យុទ្ធនាការសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិមនុស្សគ្រប់រូបក្នុងការរស់នៅដោយគ្មានអំពើហិង្សានិងការបង្ខិតបង្ខំដោយអ្នកដទៃគឺជារឿងថ្មី។ ទើបតែ ៤០ឆ្នាំកន្លងទៅប៉ុណ្ណោះ ដែលស្ត្រីនៅជុំវិញពិភពលោកបានចលនាអំពាវនាវឲ្យមានការយកចិត្តទុកដាក់ទៅលើអំពើហិង្សាផ្នែកយេនឌ័រ ថាជាបញ្ហាសិទ្ធិមនុស្ស និងសុខភាពស្ត្រីមួយដែរ។ ជាលទ្ធផល មានយុទ្ធនាការជាតិនិងអន្តរជាតិជាច្រើនដែលមានគោលបំណងបង្ហាញពីភាពអយុត្តិធម៌នៃអំពើហិង្សាផ្នែកយេនឌ័រ និងប្រមូលការគាំទ្រដើម្បីធ្វើការផ្លាស់ប្តូរច្បាប់ ទំនៀមទម្លាប់ និងប្រពៃណីដែលអនុញ្ញាតឲ្យមានអំពើហិង្សា។

បុរសមួយចំនួនក៏បានដើរតាមការដឹកនាំរបស់ស្ត្រីផងដែរ ហើយពួកគេកំពុងរៀបចំសហការជាមួយបុរសនៅក្នុងសហគមន៍របស់ខ្លួនដើម្បីជួយបំបែកលំនាំនៃអំពើហិង្សានេះ។ បុរសទាំងនេះយល់ឃើញថា វាជាការសំខាន់ដែលត្រូវចាប់ផ្តើមកិច្ចពិភាក្សាដែលស្នើឲ្យប្រជាជនគិតគូរអំពីសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការរស់នៅដោយគ្មានអំពើហិង្សា ហើយស្នើឲ្យពួកគេសាកសួរពីមូលហេតុដែលនាំឲ្យសិទ្ធិនោះគួរតែខុសប្លែកសម្រាប់បុរសជាងសម្រាប់ស្ត្រី។

នៅឆ្នាំ១៩៩១ យុទ្ធនាការបូពណ៌សត្រូវបានបង្កើតឡើងដោយបុរសមួយក្រុមនៅក្នុងប្រទេសកាណាដា ក្រោយពីនិស្សិតស្រី ១៤នាក់ត្រូវបានខ្មាន់កាំភ្លើងម្នាក់បាញ់សម្លាប់នៅឯសាកលវិទ្យាល័យម៉ុងត្រេអាល់ ។ ចាប់តាំងពីពេលនោះមក យុទ្ធនាការនេះបានសាយភាយទៅដល់ប្រទេសជាង៦០ នៅជុំវិញពិភពលោក។ បច្ចុប្បន្ន វាគឺជាកិច្ចខិតខំប្រឹងប្រែងពីបុរស ដែលវាធំជាងគេបង្អស់នៅលើពិភពលោក ដែលស្វះស្វែងឲ្យមានការបញ្ចប់អំពើហិង្សាលើស្ត្រី។ ជារៀងរាល់ឆ្នាំនៅក្នុងខែវិច្ឆិកា និងខែធ្នូ បុរសនៅជុំវិញពិភពលោក ពាក់បូពណ៌សជានិមិត្តរូបនៃការសន្យាផ្ទាល់ខ្លួនរបស់ពួកគេប្រឆាំងនឹងអំពើហិង្សា។ ពួកគេក៏បានរៀបចំព្រឹត្តិការណ៍អប់រំនិងក្រុមគាំទ្រ និងប្រើប្រាស់បណ្តាញសារព័ត៌មានគ្រប់ប្រភេទ ដើម្បីផ្សព្វផ្សាយទៅដល់មនុស្សឲ្យបានច្រើនបំផុត។ ប្រសិនបើក្រុមមួយអាចហៅមនុស្សជាច្រើននៅក្នុងសហគមន៍ មកចូលរួមក្នុងយុទ្ធនាការនេះ នោះវាអាចនាំឲ្យមានការពិភាក្សាជាច្រើន។



# សិល្បៈនិងសារព័ត៌មាន បំបែកភាពស្ងប់ស្ងាត់ចំពោះអំពើហិង្សា




ភាពស្ងប់ស្ងាត់ចំពោះអំពើហិង្សាផ្នែកយេនឌ័រ បង្កភាពងាយស្រួលឲ្យបុរសដែលចូលចិត្តប្រើហិង្សា បន្តវាយធ្វើបាបមនុស្សស្រី និងក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបី ជាបន្តទៀត។ ប្រសិនបើយើងមិនក្រោកឈរឡើង និងនិយាយថា អំពើហិង្សាលើស្ត្រីគឺជារឿងខុសឆ្គងទេ នោះអ្នកប្រើហិង្សាទទួលបានសារមួយដែលថា ឥរិយាបថរបស់ពួកគេគឺជារឿងធម្មតា និងអាចឲ្យទទួលយកបាន។ ភាពស្ងប់ស្ងាត់ក៏ផ្តល់ឲ្យជនរងគ្រោះនូវសារមួយដែលថា គ្មាននរណាម្នាក់ខ្វល់ពីពួកគេ ឬការឈឺចាប់របស់ពួកគេនោះទេ។ មានមធ្យោបាយជាច្រើនដើម្បីបើកភ្នែករបស់មនុស្សឲ្យមើលឃើញអំពើហិង្សានៅក្នុងសហគមន៍និងគ្រួសាររបស់ពួកគេ រួចនិយាយថា "យើងជាសហគមន៍មួយដែលប្រឆាំងនឹងអំពើហិង្សា!"

តន្ត្រីប្រជាប្រិយ វិទ្យុ ទូរទស្សន៍ និងអ៊ីនធឺណិត អាចផ្សព្វផ្សាយដល់មនុស្សជាច្រើនជាមួយនឹងសារលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន។

**កម្មវិធី** Breakthrough India បានបង្កើតយុទ្ធនាការផ្សព្វផ្សាយដ៏ធំមួយ ដោយប្រើប្រាស់វិទ្យុ វីដេអូ ខិតប័ណ្ណ ក្តារប្រកាសព័ត៌មាន និងកិច្ចប្រជុំក្នុងក្រុង ដើម្បីផ្សព្វផ្សាយសារ "ស្ត្រីមានសិទ្ធិរស់នៅដោយគ្មានអំពើហិង្សា" និងបង្ហាញពីប្រជាជនដែលកំពុងចាត់វិធានការបញ្ឈប់អំពើហិង្សាផ្នែកយេនឌ័រ។ វីដេអូតន្ត្រីមួយ និងអាល់ប៊ុលបទចម្រៀងដ៏ល្បីមួយឈ្មោះ "Mann ke Manjeeré" ឬបកប្រែជាភាសាខ្មែរថា "អំពើហិង្សាលើស្ត្រី" ត្រូវបានប្រជាជនទស្សនា ឬស្តាប់រាប់លាននាក់ និងមានប្រជាប្រិយភាពខ្លាំងក្នុងចំណោមយុវវ័យ។ អាល់ប៊ុមនិងវីដេអូតន្ត្រីនេះផលិតឡើងដោយផ្អែកលើរឿងរ៉ាវពិតរបស់ស្ត្រីម្នាក់ដែលរត់ចេញពីប្តីដែលចូលចិត្តប្រើហិង្សា ទៅធ្វើការជាអ្នកបើករថយន្តសណ្តោង ដើម្បីចិញ្ចឹមកូនៗរបស់នាង។






សហគមន៍ជាច្រើនបានបង្កើតបទចម្រៀនផ្ទាល់ខ្លួនរបស់ពួកគេ សារព័ត៌មាន ឬសកម្មភាពក្រៅផ្លូវការដែលជាផ្នែកមួយនៃយុទ្ធនាការនេះ។ ជាឧទាហរណ៍ ក្មេងប្រុសជំទង់មួយក្រុមបានសម្រេចចិត្តទៅមើលទូរទស្សន៍រាល់យប់នៅផ្ទះអ្នកជិតខាងម្នាក់ ដើម្បីបញ្ឈប់គាត់មិនឲ្យវាយធ្វើបាបប្រពន្ធគាត់។



**គម្រោង Puntos de Encuentro** នៅក្នុងប្រទេសនីការ៉ាគ័រ ផលិតកម្មវិធីទូរទស្សន៍រយៈពេល ៣០នាទី ក្នុងមួយសប្តាហ៍ ដែលមានឈ្មោះថា "Sexto Sentido" ឬបកប្រែជាភាសាខ្មែរថា "វិញ្ញាណទីប្រាំមួយ" ដែលសំដែងអំពីបញ្ហាផ្សេងៗ ដូចជាទំនាក់ទំនងផ្លូវភេទ និងទំនោរផ្លូវភេទ និងក៏បានបញ្ចូលអំពើហិង្សា និងរំលោភសេពសន្ថវៈផងដែរ។ កម្មវិធីនេះបានបង្ហាញពីជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សវ័យក្មេងមួយក្រុមខណៈដែលពួកគេដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងរបស់ពួកគេ។ រឿងរ៉ាវទាំងនោះត្រូវបានលាតត្រដាងនៅក្នុងកម្មវិធីចាក់ផ្សាយជាច្រើន ដែលធ្វើឲ្យកាន់តែដូចរឿងរ៉ាវពិតៗ និងប្រទាក់ក្រឡា ព្រមទាំងញ៉ាំងឲ្យមានអារម្មណ៍រីករាយនិងរំភើបផងដែរ។




**កម្មវិធី Raising Voices** នៅក្នុងប្រទេសអ៊ូហ្គង់ដា ប្រើប្រាស់វិទ្យុសហគមន៍ដើម្បីផ្តល់ព័ត៌មាន និងប្រធានបទសម្រាប់ពិភាក្សាអំពីអំពើហិង្សាលើស្ត្រី។ កម្មវិធីទាំងនោះរួមមានសេចក្តីប្រកាសព័ត៌មានសេវាសាធារណៈអំពីសេវាគាំទ្រសម្រាប់ស្ត្រី។

**ព្រឹត្តិប័ត្រព័ត៌មាន គេហទំព័រ និងទស្សនាវដ្តី** អាចបង្ហាញពីសិល្បៈ និងកំណាព្យ ព្រមទាំងចែករំលែកបទពិសោធន៍ គំនិត យុទ្ធសាស្ត្ររៀបចំចាត់ចែង និងសំណួរពីមិត្តអ្នកអានអំពីអំពើហិង្សាផ្អែកយេនឌ័រ។ ព័ត៌មានដែលត្រូវបានចែករំលែកតាមវិធីនេះអាចផ្តល់ការគាំទ្រជាលក្ខណៈឯកជន និងទូទាំងសហគមន៍នៅជុំវិញពិភពលោក។

**សិល្បៈតាមផ្លូវ** ដូចជាជញ្ជាំងផ្ទាំងគំនូរនៅតាមសហគមន៍ និងការសំដែងនៅតាមទីសាធារណៈ អាចលើកទឹកចិត្តឲ្យមនុស្សគិតគូរ និងនិយាយអំពីអំពើហិង្សាផ្អែកយេនឌ័រ។ គម្រោងសិល្បៈមួយនៅក្នុងទីក្រុងមិកស៊ិកបានប្រើប្រាស់រូបម៉ានីកាំងបុរស និងស្ត្រី ដូចជារូបម៉ានីកាំងដែលគេយកទៅតាំងបង្ហាញសម្លៀកបំពាក់នៅតាមហាងជាដើម។ រូបម៉ានីកាំងទាំងនេះត្រូវបានដាក់នៅលើឆាកសំដែង ដែលគេដំឡើងនៅតាមសួនក្នុងទីក្រុង និងនៅខាងក្រៅស្ថានីយផ្លូវក្រោមដី។ ឆាកសំដែងទាំងនេះបានបង្ហាញស្ថានភាពដែលស្ត្រីត្រូវបានប្រើប្រាស់ជាឧបករណ៍នៃអំពើហិង្សា នៅជាប់បុរសនៅក្នុងការសំដែងពី "អំពើហិង្សា" ដែលប្រព្រឹត្តតាមវិធីផ្សេងៗ។



នៅពេលខ្លះ រូបម៉ានីកាំងត្រូវបានដាក់តាំងនៅក្នុងស្ថានភាពជាក់ស្តែង ដូចជាបុរសកំពុងវាយស្ត្រីជាដើម។ ជាឧទាហរណ៍ រូបម៉ានីកាំងបុរស មើលទៅដូចជាកំពុងសំឡឹងមើលទៅលើរាងកាយរូបម៉ានីកាំងស្ត្រីដែលពោរពេញទៅដោយសមចាក់ដោតដែលហាក់បីដូចជាគាត់កំពុងទទួលទានរូបនាង។ ឈុតឆាកមួយចំនួនមានលក្ខណៈបែបកំប្លែង ប៉ុន្តែឈុតឆាកជាច្រើនមើលទៅដូចជាបង្ហាញនូវភាពតក់ស្លុត។ ក្រដាសនិងហ្វឺតត្រូវបានរៀបចំដាក់នៅលើតុ ដើម្បីឲ្យមនុស្សដែលដើរកាត់អាចសរសេរបង្ហាញពីគំនិត ឬអារម្មណ៍របស់ពួកគេ រួចកឹបក្រដាសនេះភ្ជាប់ទៅនឹងខ្សែព្យួរខោអាវ ដែលអាចឲ្យអ្នកដទៃអាននិងពិភាក្សាបាន។

## សាលសំដែងបង្កលក្ខណៈងាយស្រួលឱ្យចូលរួម

ក្រុមអង្គការនានានៅជុំវិញពិភពលោកប្រើប្រាស់សាលសំដែង បង្កលក្ខណៈងាយស្រួលឲ្យចូលរួម ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីទស្សនិកជនទៅលើអំពើហិង្សាផ្អែកយេនឌ័រ។ ក្រុមមួយចំនួនអនុញ្ញាតឲ្យអ្នករួចរស់រានពីអំពើហិង្សាឬអ្នកសំដែង សំដែងចេញនូវរឿងរ៉ាវរបស់ពួកគេ។ បន្ទាប់មក ពួកគេដឹកនាំទស្សនិកជននៅក្នុងការពិភាក្សាពីអំពើហិង្សា។ ក្រុមមួយចំនួនទៀតអនុញ្ញាតឲ្យទស្សនិកជន ទស្សនាការសំដែងពីស្ថានភាពមួយដែលប្រែក្លាយជាហិង្សា រួចស្នើឲ្យពួកគេបញ្ចេញមតិយោបល់ ឬផ្លាស់ប្តូរអ្វីដែលពួកគេមើលឃើញ។



**ក្រុម Ambush Theatre** នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសផ្សេងទៀត បានរៀបចំឲ្យបុរស និងស្ត្រីនៃបណ្តាញយុត្តិធម៌យេនឌ័រ Sonke (Sonke Gender Justice Network) ធ្វើការសំដែងនូវឈុតឆាកនៃអំពើហិង្សាផ្លូវអារម្មណ៍ ឬហិង្សាដោយពាក្យសម្តីនៅទីសាធារណៈ ដែលគ្មាននរណារំពឹងថានឹងបានឃើញ។ នៅពេលដែលហ្វូងមនុស្សប្រមូលផ្តុំមកទស្សនាការសំដែង ក្រុមនេះក៏បានប្រើប្រាស់ឱកាសដ៏ល្អនេះដើម្បីនិយាយអំពីអំពើហិង្សា និងអំពើរំលោភសេពសន្ថវៈ។ បន្ទាប់មក តួសំដែងក៏សំដែងឈុតឆាកនោះម្តងទៀត ដោយស្នើឲ្យទស្សនិកជនស្រែកថា "ឈប់!" នៅពេលដែលពួកគេចង់ឲ្យតួសំដែងនិយាយអ្វីផ្សេង ឬធ្វើសកម្មភាពដែលគ្មានហិង្សាវិញ។

# ការចែករំលែករឿងរ៉ាវពិតអំពីអំពើហិង្សាតាមរយៈសិល្បៈ

ការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនជាមួយអំពើហិង្សា ជួយឲ្យមនុស្សបន្ថយការស្តីបន្ទោសលើខ្លួនឯង និងលុបបំបាត់ស្លាកស្នាម ដើម្បីក្លាយខ្លួនជាអ្នករួចរស់រានពីអំពើហិង្សា មិនមែនជាជនរងគ្រោះនៃអំពើហិង្សាឡើយ។ ការទស្សនាសិល្បៈអំពីអំពើហិង្សា ក៏អាចជួយជួយត្រិះរិះអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេផងដែរ ហើយព្យាបាលអ្នករួចរស់រាន ជាមួយនឹងសេចក្តីអាណិតស្រឡាញ់កាន់តែខ្លាំង។ សិល្បៈក៏អាចជាមធ្យោបាយដ៏មានឥទ្ធិពលមួយសម្រាប់ប្រើប្រាស់ ដើម្បីជំរុញឲ្យមនុស្សហ៊ាននិយាយប្រឆាំងនឹងអំពើអយុត្តិធម៌។

**ការប្រកួតប្រជែងបង្កើតផ្ទាំងផ្សព្វផ្សាយ ការប្រកួតប្រជែងតែងកំណាព្យ និងការតាំងបង្ហាញសិល្បៈ** អាចលើកទឹកចិត្តឲ្យកុមារ និងមនុស្សធំ ចែករំលែកពីគំនិតនិងអារម្មណ៍របស់ពួកគេ ពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកយេនឌ័រ មិនថាពួកគេបានឮអំពីវា មើលឃើញវា ឬធ្លាប់ឆ្លងកាត់វានោះទេ។ ការតាំងបង្ហាញសិល្បៈ អាចធ្វើឡើងដោយគ្មានឈ្មោះមនុស្សភ្ជាប់ជាមួយក៏បាន ប្រសិនបើធ្វើដូច្នេះជួយលើកទឹកចិត្តឲ្យមនុស្សកាន់តែច្រើនមកចូលរួម។

**សៀវភៅរឿងជាគំនូរ** អាចបង្ហាញពីស្ថានភាពជីវិតពិតដែលធ្វើឲ្យមនុស្សគិតអំពីមូលហេតុដែលនាំឲ្យកើតមានអំពើហិង្សា អារម្មណ៍របស់អ្នកនៅក្នុងសាច់រឿង និងរបៀបដែលរឿងរ៉ាវទាំងនោះគួរតែមានការផ្លាស់ប្តូរ។



## វីដេអូ "តាមរយៈភ្នែករបស់យើង" បង្ហាញពីអំពើហិង្សា និងការរំលោភសេពសន្ថវៈ នៅក្នុងប្រទេសលីបេរីយ៉ា

នៅក្នុងអំឡុងសង្គ្រាមស៊ីវិលរយៈពេល១៤ឆ្នាំ នៅក្នុងប្រទេសលីបេរីយ៉ា ទ្វីបអាហ្រ្វិកខាងលិច ទាហានបានប្រើប្រាស់អំពើហិង្សាផ្លូវភេទលើស្ត្រី ដើម្បីបង្វែរឲ្យក្រុមមួយប្រឆាំងនឹងក្រុមមួយទៀត។ ពួកទាហានបានរំលោភសេពសន្ថវៈលើស្ត្រីនិងក្មេងស្រីរាប់ពាន់នាក់។ ក្រោយពីសង្គ្រាមបានបញ្ចប់នៅក្នុងឆ្នាំ២០០៣ អំពើហិង្សាផ្លូវភេទមិនបានបញ្ចប់នោះទេ។ ក្មេងស្រីត្រូវបានបង្ខំឲ្យរៀបការទាំងវ័យក្មេង។ បុរសជាច្រើនជឿថា ការវាយប្រពន្ធដែលមិនគោរពពួកគេគឺជារឿងត្រឹមត្រូវ ហើយការរំលោភសេពសន្ថវៈគឺជារឿងធម្មតា។ ស្ត្រីមួយចំនួនចង់និយាយអំពីរបៀបស្វែងរកសុវត្ថិភាពពីអំពើហិង្សាផ្លូវភេទ ប៉ុន្តែមានមនុស្សជាច្រើនបដិសេធថា មិនមានបញ្ហានោះទេ។



ដើម្បីចាប់ផ្តើមការពិភាក្សាសហគមន៍អំពីអំពើហិង្សាលើស្ត្រីនៅតាមតំបន់ដែលរងគ្រោះបំផុតពីសង្គ្រាម គម្រោង "តាមរយៈភ្នែករបស់យើង" បានបណ្តុះបណ្តាលស្ត្រីនិងបុរសជាច្រើនក្រុម អំពីការប្រើប្រាស់កាមេរ៉ាវីដេអូដើម្បីផលិតខ្សែភាពយន្តខ្លីស្តីអំពីអំពើហិង្សាផ្អែកយេនឌ័រ និងពីសេវាសម្រាប់អ្នករួចរស់រានផងដែរ។ សមាជិកសហគមន៍គឺជាតួសំដែងនៅក្នុងវីដេអូទាំងនេះដែលបង្ហាញពីរបៀបផ្សេងៗដែលស្ត្រីនិងក្មេងស្រីបានរងគ្រោះពីអំពើហិង្សា រួមទាំងការអនុវត្តបែបប្រពៃណី ការបង្ខំឲ្យរៀបការទាំងវ័យក្មេង ការបំពានផ្លូវភេទនិងការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវកាយផងដែរ។ នៅពេលដែលចាក់បញ្ចាំងវីដេអូទាំងនេះនៅក្នុងសហគមន៍ ពួកវាបានជួយឲ្យមានការចាប់ផ្តើមការពិភាក្សាអំពីបញ្ហាដែលគេកម្រនឹងលើកឡើងនៅតាមទីសាធារណៈ។ មួយសន្ទុះក្រោយមក មានស្ត្រីនិងក្មេងស្រីជាច្រើនបានចាប់ផ្តើមដើរមកកាន់ក្រុមគម្រោងដើម្បីរាយការណ៍ពីអំពើហិង្សា និងស្វែងរកការពិគ្រោះយោបល់ ។

មិនថាការផលិតឬការទស្សនាវីដេអូទាំងនេះទេ ក្រុមស្ត្រីរួចរស់រានពីអំពើហិង្សានិយាយនៅពេលនេះថា ពួកគេមានអារម្មណ៍ថាពួកគេមិនឯកោទេ ហើយពួកគេក៏បន្ថយការស្តីបន្ទោសលើខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។ ពួកគេមើលឃើញអ្វីដែលពួកគេមានដូចគ្នា ជាមួយស្ត្រីដទៃទៀតដែលបានជួបប្រទះរឿងរ៉ាវស្រដៀងគ្នា។ ហើយដោយសារតែភាពជោគជ័យនៅក្នុងប្រទេសលីបេរីយ៉ា គម្រោងវីដេអូតាមរយៈភ្នែករបស់យើង ក៏ត្រូវបានយកទៅអនុវត្តនៅតាមបណ្តាប្រទេសជាច្រើនផ្សេងទៀតផងដែរ។




សិក្ខាកាមវគ្គបណ្តុះបណ្តាលជំនាញថតវីដេអូជនជាតិលីបេរីយ៉ា

# សកម្មភាពសហគមន៍ដើម្បីគាំទ្រអ្នករួចរស់រានពីអំពើហិង្សា

ជាធម្មតា ចលនាដើម្បីបញ្ចប់អំពើហិង្សាផ្អែកយេនឌ័រ ចាប់ផ្តើមជាមួយនឹងការស្វែងរកវិធីដើម្បីជួយអ្នករួចរស់រានពីអំពើហិង្សា។ ជាឧទាហរណ៍ គេបង្កើតជម្រក និងមណ្ឌលដោះស្រាយអ្នកមានវិបត្តិពីអំពើរំលោភសេពសន្ថវៈ ដើម្បីជួយស្ត្រីឲ្យគេចផុតពីអំពើហិង្សា។ ទីកន្លែងផ្សេងៗ ដូចជា មជ្ឈមណ្ឌលឬហាងកាហ្វេសំចត អាចជាទីកន្លែងសម្រាប់ឲ្យក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបី ទៅស្វែងរកជំនួយនិងសុវត្ថិភាព ចៀសផុតពីអំពើហិង្សា ឬគ្រាន់តែទៅដើម្បីទទួលបាននូវអារម្មណ៍កក់ក្តៅ។ នៅពេលដែលមនុស្សរងគ្រោះពីអំពើហិង្សាផ្អែកយេនឌ័រ ទទួលបានសុវត្ថិភាពពីគ្រោះថ្នាក់ភ្លាមៗ នោះសហគមន៍អាចបន្តទៅជួយបង្កើតផែនការរយៈពេលវែងសម្រាប់កិច្ចការពារបន្ត ការជាសះស្បើយ និងឯករាជ្យភាពសម្រាប់អ្នករួចរស់រានពីអំពើហិង្សា។

## គាំទ្រអ្នករួចរស់រាន ដើម្បីគេចចេញពីអំពើហិង្សាក្នុងគ្រួសារ

ការគាំទ្រស្ត្រីដើម្បីគេចចេញពីទំនាក់ទំនងប្រកបដោយហិង្សា អាចជួយសង្គ្រោះជីវិតពួកគេបាន។ ចូរចែករំលែកជំហានទាំងនេះជាមួយស្ត្រីដទៃទៀត និងស្នើឲ្យពួកគេចែករំលែកបន្តទៅកាន់ស្ត្រីដែលអាចនឹងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់៖

**នៅមុនពេលអំពើហិង្សាកើតឡើងម្តងទៀត** ចូរប្រាប់នរណាម្នាក់នៅក្បែរឲ្យបានដឹងជាមុន។ ស្នើឲ្យបុគ្គលរូបនោះមកជួយ ឬស្វែងរកជំនួយ ប្រសិនបើគាត់ឮថាអ្នកកំពុងជួបគ្រោះថ្នាក់។ បុគ្គលរូបនោះអាចជាអ្នកជិតខាត សាច់ញាតិប្រុស ឬក្រុមស្ត្រីឬបុរសដែអាចមកជួយអ្នកមុនពេលដែលអ្នកទទួលរងការវាយដំធ្ងន់ធ្ងរ។ ចូរគិតអំពីពាក្យឬសញ្ញាពិសេសណាមួយដែលនឹងប្រាប់កូនៗរបស់អ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកឲ្យស្វែងរកជំនួយ។ បង្រៀនកូនៗរបស់អ្នកឲ្យចេះស្វែងរកកន្លែងមានសុវត្ថិភាព។

**នៅពេលដែលបុរសប្រើហិង្សា** ចូរព្យាយាមរត់ទៅកាន់ ឬបន្តនៅកន្លែងដែលគ្មានអាវុធឬវត្ថុដែលគាត់អាចប្រើដើម្បីវាយធ្វើបាបរូបអ្នកបាន។ ធ្វើអ្វីដើម្បីរម្ងាប់អារម្មណ៍ខឹងសម្បាររបស់គាត់ ដើម្បីឲ្យខ្លួនអ្នកនិងកូនៗរបស់អ្នកមានសុវត្ថិភាព។ ប្រសិនបើអ្នកចាំបាច់រត់គេចចេញពីគាត់ ចូរគិតគូរពីរបៀបដែលអ្នកអាចគេចខ្លួនបាន។ តើទីកន្លែងណាដែលមានសុវត្ថិភាពបំផុតសម្រាប់ឲ្យអ្នកទៅ?

**ត្រៀមខ្លួនដើម្បីចាកចេញ** ៖ សន្សំប្រាក់តាមវិធីដែលអ្នកអាចធ្វើបាន។ ដាក់ប្រាក់នៅកន្លែងដែលមានសុវត្ថិភាពឆ្ងាយពីផ្ទះ។ ប្រសិនបើអាច បើកគណនីធនាគារដោយដាក់ឈ្មោះផ្ទាល់ខ្លួនរបស់អ្នក។ ចូរព្យាយាមធ្វើកិច្ចការផ្សេងទៀតដើម្បីឲ្យអ្នកកាន់តែមានភាពឯករាជ្យ ដូចជាបង្កើតមិត្ត ចូលរួមក្រុម ឬចំណាយពេលវេលាបន្ថែមជាមួយគ្រួសាររបស់អ្នក។

ស្វែងយល់ថាតើមាន "ផ្ទះសុវត្ថិភាព" ឬសេវាផ្សេងទៀតនៅជិតៗសម្រាប់ឲ្យស្ត្រីដែលរងគ្រោះប្រើប្រាស់ដែរឬអត់។ ចូររៀនពីរបៀបដែលសេវាទាំងនេះអាចជួយអ្នកបាន។ សួរមិត្តភ័ក្តិ ឬសាច់ញាតិដែលអ្នកជឿទុកចិត្តថាតើពួកគេអាចអនុញ្ញាតឲ្យអ្នកស្នាក់នៅជាមួយ ឬខ្ចីប្រាក់បានដែរឬយ៉ាងណា។ ចូរប្រាកដថា ពួកគេនឹងមិនប្រាប់អ្នកប្រើហិង្សាលើអ្នកថា អ្នកបានសួរ ឬប្រាប់ពីកន្លែងដែលអ្នកទៅស្នាក់នៅនោះទេ។

ស្វែងរកឯកសារសំខាន់ៗ ដូចជាឯកសារសម្គាល់ខ្លួនរបស់អ្នក និងកូនៗរបស់អ្នក។ ទុកដាក់ប្រាក់កាស ឯកសាររបស់អ្នក និងសម្លៀកបំពាក់ជាមួយនរណាម្នាក់ដែលអ្នកជឿទុកចិត្ត ដើម្បីឲ្យអ្នកអាចចាកចេញបានឆាប់។ ប្រសិនបើអ្នកអាចធ្វើវាបានដោយសុវត្ថិភាព ចូរសាកល្បងអនុវត្តផែនការរត់គេចខ្លួនរបស់អ្នកជាមួយកូនៗរបស់អ្នក ដើម្បីពិនិត្យមើលថាផែនការនោះនឹងមានប្រសិទ្ធភាពដែរឬយ៉ាងណា។ ចូរប្រាកដថា កូនៗរបស់អ្នកនឹងមិនប្រាប់នរណាម្នាក់ទេ។ (សូមមើលសៀវភៅ ទីណាស្ត្រីគ្មានវេជ្ជបណ្ឌិត ទំព័រ 321 ដល់ 325)។

# បុគ្គលិកសុខាភិបាលគាំទ្រអ្នករួចរស់រានពីអំពើហិង្សាផ្លូវភេទ

បុគ្គលិកសុខាភិបាលអាចរៀបចំ និងចូលរួមសកម្មភាពគ្រប់ប្រភេទដើម្បីបញ្ឈប់អំពើហិង្សា ប៉ុន្តែវាកាន់តែមានសារៈសំខាន់ខ្លាំងថែមទៀតបើពួកគេអាចគាំទ្រជនរងគ្រោះពីអំពើហិង្សាផ្អែកយេនឌ័រដែលបានរងការវាយដំ រំលោភសេពសន្ថវៈ ឬបំពាន។ ទន្ទឹមនឹងការព្យាបាលរបួសស្នាម បុគ្គលិកសុខាភិបាលក៏អាចបញ្ជូនជនរងគ្រោះទៅកាន់ធនធានសហគមន៍ដទៃទៀត ដូចជាក្រុមគាំទ្រ និងជម្រកស្នាក់នៅផងដែរ។

ស្ត្រីដែលចង់ដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកប្រើហិង្សា ឬជនរំលោភសេពសន្ថវៈ ចាំបាច់ត្រូវកត់ត្រារបួសស្នាមឬគ្រោះថ្នាក់ផ្សេងទៀតដែលបណ្តាលមកពីអំពើហិង្សាទុកជាឯកសារ។ បុគ្គលិកសុខាភិបាលគួរចេះរបៀបធ្វើកិច្ចការនេះ រួមជាមួយនឹងការយកចិត្តទុកដាក់ទៅលើតម្រូវការសុខភាពរបស់ស្ត្រីផងដែរ។ (សម្រាប់ព័ត៌មានពិស្តារបន្ថែម សូមមើលសៀវភៅ ទីណាស្ត្រីគ្មានវេជ្ជបណ្ឌិត ទំព័រ 335)។

ដើម្បីផ្តល់ការថែទាំប្រកបដោយការគោរពបំផុត ជូនអ្នករួចរស់រានពីអំពើហិង្សាផ្លូវភេទ ចូរអនុវត្តដូចខាងក្រោមៈ




- ប្រសិនបើជនរងគ្រោះជាស្ត្រី ចូរប្រាកដថា បុគ្គលិកសុខាភិបាលស្រីជាអ្នកពិនិត្យរាងកាយរបស់នាង។
- រក្សាឈ្មោះនិងព័ត៌មានផ្សេងទៀតរបស់ជនរងគ្រោះជាការសម្ងាត់ និងប្រាប់ពួកគេថាអ្នកនឹងមិនចែករំលែកព័ត៌មានទាំងនេះទៅដល់អ្នកដទៃទេ។
- ផ្តល់កន្លែងដែលមានផាសុកភាព និងអាចធ្វើដំណើរទៅដល់បាន សម្រាប់ឲ្យជនរងគ្រោះអាចរាយការណ៍ពីអំពើរំលោភសេពសន្ថវៈ ឬការវាយប្រហារ និងប្រុងប្រយ័ត្នដោយមិនត្រូវស្តីបន្ទោសពួកគេចំពោះអំពើហិង្សាដែលបានកើតឡើងលើរូបគេនោះទេ។
- ពន្យល់ពីមធ្យោបាយពន្យារកំណើតបន្ទាន់ និងជួយស្ត្រីឲ្យចេះប្រើប្រាស់វា ប្រសិនបើនាងជ្រើសរើស។ (សូមមើលទំព័រ 194)
- ប្រសិនបើចាំបាច់ ចូរផ្តល់ថ្នាំបង្ការការចម្លងជំងឺកាមរោគ រួមទាំងមេរោគអេដស៍ផងដែរ។

*នៅពេលខ្លះ អ្នកអាចនឹងធ្វើការជាមួយអ្នកជំងឺដែលមានទំនោរផ្លូវភេទនិងយេនឌ័រខុសប្លែកពីអ្នកជំងឺដែលអ្នកធ្លាប់ជួប ដូចជាមនុស្សដែលមានភាពជាបុរសឬជាស្ត្រីច្រើនជាងអ្វីដែលអ្នករំពឹងទុក ឬអ្នកដែលចាប់អារម្មណ៍តែចំពោះមនុស្សភេទដូចគ្នា។ ប្រសិនបើអ្នកមិនប្រាកដថាអ្នកជំងឺរបស់អ្នកមានភេទអ្វីទេ អ្នកអាចសួរឈ្មោះរបស់គាត់ដោយសុភាពរាបសា ហើយប្រសិនបើពួកគេមានពាក្យសម្រាប់សម្គាល់ភេទរបស់គាត់ ហើយដែលគាត់ចូលចិត្ត ចូរប្រាកដប្រើពាក្យនោះផងដែរ។ ពួកគេមានសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ ឯកជនភាព និងការថែទាំដូចគ្នានឹងអ្នកដទៃទៀតដែរ!*



# ក្រុមគាំទ្រគ្នាទៅវិញទៅមក

អ្នកដែលរួចរស់រានពីអំពើហិង្សាឬអំពើរំលោភសេពសន្ថវៈត្រូវការការគាំទ្រពីគ្រួសារ និងសហគមន៍របស់ពួកគេ។ ជាអកុសល្យ អ្នករួចរស់រានពីអំពើហិង្សា ជាពិសេសអ្នករួចរស់រានពីអំពើរំលោភសេពសន្ថវៈ ជារឿយៗត្រូវបានគេបដិសេធ និងរើសអើង។




ការបង្កើតសាមគ្គីភាពជាមួយអ្នកដែលរងគ្រោះពីអំពើហិង្សា គឺជាវិធីដ៏មានប្រសិទ្ធភាពដើម្បីកាត់បន្ថយផលប៉ះពាល់ ជាពិសេសឥទ្ធិពលរយៈពេលយូរអង្វែង។

គ្មាននរណាម្នាក់យល់ពីការតស៊ូដែលស្ត្រីរងគ្រោះជួបប្រទះ ច្បាស់ជាងអ្នករួចរស់រានពីអំពើហិង្សាដទៃទៀតនោះទេ។ នៅពេលដែលស្ត្រីសាមគ្គីគ្នានៅក្នុងក្រុមគាំទ្រគ្នាទៅវិញទៅមក នោះពួកគេមានអារម្មណ៍ថាខ្លួនមិនឯកាទៀតទេ។ ពួកគេអាចប្រាប់រឿងរ៉ាវរបស់ពួកគេដោយគ្មានការភ័យខ្លាចពីការវិនិច្ឆ័យ។ ពួកគេក៏អាចចែករំលែកយុទ្ធសាស្ត្រដោះស្រាយបញ្ហា និងព័ត៌មានអំពីទីកន្លែងស្វែងរកជំនួយផងដែរ។

រឿងដូចគ្នានេះក៏ត្រឹមត្រូវផងដែរសម្រាប់ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំងពីរ និងមនុស្សភេទទីបីដែលទទួលរងការវាយធ្វើបាប រំលោភសេពសន្ថវៈ ឬបំពានដោយសារតែចំណង់ផ្លូវភេទ ឬអត្តសញ្ញាណភេទរបស់ពួកគេ។ តាមរយៈការជួបជាមួយអ្នកដែលមានបទពិសោធន៍ប្រហាក់ប្រហែល មនុស្សដែលរងគ្រោះពីអំពើហិង្សាអាចយល់ថា ពួកគេមិនមែនមានតែម្នាក់នោះទេ ពួកគេអាចរៀនសូត្រពីគ្នាទៅវិញទៅមក និងស្វែងរកចំណុចខ្លាំងនិងអំណាចដែលពួកគេត្រូវការដើម្បីជាសះស្បើយ។

## គាំទ្រអ្នករួចរស់រានពីជម្លោះប្រដាប់អាវុធ

នៅក្នុងសង្គ្រាមនិងជម្លោះហិង្សាដទៃទៀត នៅពេលដែលក្រុមបុរសប្រជែងគ្នាដើម្បីគ្រប់គ្រងអំណាចលើដែនដី ធនធាន និងទ្រព្យសម្បត្តិក្នុងទម្រង់ផ្សេងៗទៀត ស្ត្រីនិងកុមារក្លាយជាគោលដៅសម្រាប់ការវាយប្រហារផ្លូវភេទ។ បុរសកាន់តែប្រើប្រាស់អំពើរំលោភសេពសន្ថវៈ និងអំពើរំលោភផ្លូវភេទក្នុងទម្រង់ផ្សេងៗទៀតជាអាវុធដើម្បីបង្កភាពតក់ស្លុត បន្ទាបបន្ថោក និងយកប្រៀបលើក្រុមជាសត្រូវរបស់ខ្លួន។

នៅតាមសហគមន៍ដែលខ្ទេចខ្ទាំដោយជម្លោះប្រដាប់អាវុធ ជារឿយៗស្ត្រីត្រូវបានគេមិនបញ្ចូលក្នុងក្រុមអ្នកធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំផែនការសម្រាប់ស្តារ និងកសាងសហគមន៍ឡើងវិញទេ ជាពិសេសប្រសិនបើប្រជាជនដឹងថា ពួកគេត្រូវបានរំលោភផ្លូវភេទនៅក្នុងអំឡុងពេលកើតមានជម្លោះ។ អ្នកអាចជួយស្ត្រីរៀបចំក្រុមដោយផ្តល់ឱកាសឲ្យពួកគាត់ជួបជុំគ្នា ប្រាប់រឿងរ៉ាវរបស់ខ្លួន ទទួលសេវាថែទាំសុខភាព និងសហការគ្នារៀបចំផែនការសម្រាប់ពេលអនាគត។ នៅពេលដែលអ្នករួចរស់រានក្លាយខ្លួនជាមេដឹកនាំសហគមន៍ បទពិសោធន៍របស់ពួកគេអាចជួយពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ការកុំឲ្យមានអំពើហិង្សាបន្តទៀតទៅថ្ងៃខាងមុខ។

# ការរៀបចំដើម្បីបង្ការអំពើហិង្សា

វិធានបង្ការអំពើហិង្សា មានជោគជ័យបំផុតនៅពេលដែលវារួមបញ្ចូលសហគមន៍ទាំងមូល ពោលគឺស្ត្រី បុរស មនុស្សចាស់ និងយុវជន។ ជជែកជាមួយមនុស្សគ្រប់គ្នាអំពីផលប្រយោជន៍នៃការបញ្ឈប់អំពើហិង្សាផ្នែកយេនឌ័រគ្រប់ទម្រង់ទាំងអស់។ សង្កត់ធ្ងន់ថា កិច្ចប្រឹងប្រែងដើម្បីបញ្ឈប់ហិង្សា គឺមិនមែនដើម្បីប្រឆាំងនឹងបុរសទេ ប៉ុន្តែដើម្បីសុខមាលភាពនិងសេចក្តីថ្លៃថ្នូរសម្រាប់មនុស្សគ្រប់គ្នា។

## បង្កើតផែនទីនៃគ្រោះថ្នាក់

សកម្មភាពបង្កើតផែនទី អាចជាមធ្យោបាយដ៏ល្អមួយក្នុងការចាប់ផ្តើមការរៀបចំសហគមន៍ដើម្បីបង្ការអំពើហិង្សា។ អញ្ជើញអ្នកដឹកនាំសហគមន៍ ម្ចាស់ជំនួញ និងដៃគូផ្សេងទៀត ឲ្យចូលរួមនិងដើម្បីជួយបង្កើតផែនការ។ ម្យ៉ាងទៀត ព្យាយាមរួមបញ្ចូលស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះពីអំពើហិង្សាដោយសារតែទីកន្លែងដែលពួកគេរស់នៅ ពេលវេលានិងរបៀបធ្វើដំណើរទៅធ្វើការឬសាលារៀន ឬដោយសារប្រភេទការងាររបស់ពួកគេ។ ត្រូវប្រាកដថាក្រុមស្រឡាញ់ភេទដូចគ្នា-ភេទទាំង២និងអ្នកមានភេទទី៣ បង្ហាញពីទីតាំងក្នុងសហគមន៍ដែលពួកគេគិតថាមានការប្រឈមគ្រោះថ្នាក់បំផុត។ នាំអ្នកចូលរួមទាំងអស់ដើរក្នុងសហគមន៍ រួចកត់សម្គាល់ទីតាំងដែលមានបញ្ហា បន្ទាប់មកបង្កើតផែនទីនៃគ្រោះថ្នាក់។ ក្រុមការងារអាចពិភាក្សា និងស្នើសុំការផ្លាស់ប្តូរ ដូចជាការកែលម្អភ្លើងបំភ្លឺតាមផ្លូវ ឬក្រុមសន្តិសុខសហគមន៍ជាដើម។ សម្រាប់ឧទាហរណ៍អំពីការបង្កើតផែនការសហគមន៍ សូមមើល "ការបង្កើតផែនទីនៃផ្លូវទៅកាន់មាតុភាពគ្មានគ្រោះថ្នាក់" (ទំព័រ 218)។

### កម្មករចលនាដើម្បីទាមទារឲ្យកែលម្អសុវត្ថិភាពផងផ្លូវ



កម្មការនីរោងចក្រនៅប្រទេសស្រីលង្ការស់នៅក្នុងសហគមន៍ធំមួយក្រៅតំបន់ពាណិជ្ជកម្មសេរី។ អ្នកដឹកនាំសហជីពបានស្ទង់មតិស្ត្រីអំពីការបារម្ភរបស់ពួកគេ ហើយបានស្វែងយល់ថាស្ត្រីព្រួយបារម្ភពីសុវត្ថិភាពពេលធ្វើដំណើរទៅនិងមកពីរោងចក្រនៅពេលយប់ ដោយសារករណីឆក់ប្លន់ និងរំលោភផ្លូវភេទ។ អ្នកដឹកនាំសហជីពបានជួយឲ្យស្ត្រីពិភាក្សាពីបញ្ហា ដំណោះស្រាយ និងវិធានមួយចំនួនដែលនាំឲ្យការធ្វើដំណើរមានសុវត្ថិភាព។ ពួកគេបាននាំយកសំណើររបស់ខ្លួនទៅជូនម្ចាស់រោងចក្រ ហើយទទួលបានការផ្លាស់ប្តូរមួយចំនួន ដូចជាសេវារថយន្តក្រុងសម្រាប់កម្មករនៅក្នុងតំបន់ពាណិជ្ជកម្ម និងផ្ទះកម្មករជាដើម។

## ស្ត្រីភេទទី៣ ប្រយុទ្ធដើម្បីបង្ការអំពើហិង្សាក្នុងប្រទេសកូឡុំប៊ី

នៅប្រទេសជាច្រើន ក្រុមស្រឡាញ់ភេទដូចគ្នា-ភេទទាំង២ ជាពិសេសក្រុមភេទទី៣ មានការពិបាកក្នុងការស្វែងរកការងារ ទទួលការធានារ៉ាប់រងសុខភាព និងបញ្ចប់ការសិក្សា។ សហគមន៍នៃក្រុមមនុស្សទាំងនេះ ក៏ទំនងជាទទួលរងនូវអំពើបំពានផ្លូវភេទ និងហិង្សានៅក្នុងជីវិតរបស់ពួកគេផងដែរ។ (សម្រាប់ព័ត៌មានបន្ថែមអំពីអត្តសញ្ញាណយេនឌ័រ សូមមើលទំព័រ ៤០)។

នៅប្រទេសកូឡុំប៊ី ការវាយប្រហារលើក្រុមមនុស្សទាំងនេះ កើតឡើងជាញឹកញាប់ ជាពិសេសទៅលើក្រុមស្ត្រីភេទទី៣។ នៅឆ្នាំ២០០៤ ស្ត្រីភេទទី៣ម្នាក់ឈ្មោះសាន់តាម៉ារីយ៉ា (Maria Paula Santamaría) ត្រូវបានវាយប្រហារជាទម្ងន់ រួចក៏ស្លាប់បន្ទាប់ពីមន្ទីរពេទ្យសាន់ទីអាហ្គោ បដិសេធមិនផ្តល់ការព្យាបាល។ ដើម្បីឧទ្ទិសដល់នាងម៉ារីយ៉ា មិត្តរបស់នាង៤នាក់ បានបង្កើតអង្គការមូលនីធិសាន់តាម៉ារីយ៉ា (Santamaría Fundación) ដើម្បីបង្ការកុំឲ្យរឿងដូចនេះកើតឡើងចំពោះស្ត្រីភេទទី៣ដទៃទៀតក្នុងប្រទេសកូឡុំប៊ី។

ក្នុងគម្រោងនេះ ពួកគេចាប់ផ្តើមដោយធ្វើការផ្សព្វផ្សាយព័ត៌មានអំពីរបៀបការពារខ្លួនប្រសិនបើមានវាយប្រហារ និងពីរបៀបរាយការណ៍ពីករណីបំពានណាមួយ។ ក្រុមការងារក៏បានផ្តល់នូវគន្លឹះសំខាន់ៗអំពីរបៀបរក្សាសុវត្ថិភាព និងផ្តល់ដំបូន្មានឲ្យស្ត្រីធ្វើដំណើរជាក្រុម ព្រមទាំងមានទូរស័ព្ទដែលអាចហៅចេញបានជានិច្ច ដើម្បីទាក់ទងអង្គការភ្លាមបើគិតថាកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់។ ដោយយល់ឃើញថាមន្ត្រីប៉ូលិសមួយចំនួន បំពាននិងវាយដំមនុស្សភេទទីជារឿយៗ នោះពួកគេក៏បានចាប់ផ្តើមអនុវត្ត "កម្មវិធីឃ្លាំមើលសហគមន៍" ផងដែរ ដើម្បីកត់ត្រានិងផ្សព្វផ្សាយព័ត៌មានអំពីអំពើហិង្សារបស់ប៉ូលិស រួមទាំងព័ត៌មានអំពីទីកន្លែងនិងពេលវេលាដែលការវាយដំកើតឡើងផងដែរ។

ដើម្បីបង្កើនការយល់ដឹងដល់សាធារណជនអំពីបញ្ហានេះ អង្គការ Santamaría Fundación ក៏បានចាប់ផ្តើមសាងសង់ រូបសំណាកឧទ្ទិសដល់ស្ត្រីដែលត្រូវបានសម្លាប់។ ចម្លងតាមកម្មវិធីដែលក្រសួងចរាចរណ៍បានចាប់ផ្តើមអនុវត្តរួចហើយ ដែលកត់ត្រាការស្លាប់ពីគ្រោះថ្នាក់ចរាចរណ៍ ដោយការសង់រូបសំណាកផ្កាយពណ៌ខ្មៅនៅលើផ្លូវ, ក្រុមការងារអង្គការបានសង់ជារូបសំណាកផ្កាយពណ៌ផ្កាឈូក ដាក់នៅទីកន្លែងដែលមនុស្សភេទទី៣ត្រូវបានសម្លាប់វិញ។

ក្រុមការងារបានកត់សម្គាល់ឃើញថា សម្ពាធរបស់ពួកគេទៅលើកងកម្លាំងប៉ូលិស បានធ្វើឲ្យករណីហិង្សាធ្លាក់ចុះមួយកម្រិត ប៉ុន្តែពួកគេដឹងថានៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីឲ្យមនុស្សភេទទី៣ទទួលបានការគោរពនិងសេចក្តីថ្លៃថ្នូរដូចពលរដ្ឋដទៃទៀតដែរ។

## ផ្សារភ្ជាប់ជាមួយចលនាដើម្បីយុត្តិធម៌សេដ្ឋកិច្ច

មធ្យោបាយមួយទៀតដែលសហគមន៍អាចបង្ការអំពើហិង្សាផ្នែកយេនឌ័របាន គឺតាមរយៈការចូលរួមជាមួយកិច្ចប្រឹងប្រែងដទៃទៀតដែលទាមទារប្រាក់កម្រៃស្មើភាពសម្រាប់ស្ត្រី, និងធានាថាមនុស្សគ្រប់គ្នាទទួលបានកម្រៃសមរម្យ ការគោរព និងសេចក្តីថ្លៃថ្នូរក្នុងការងាររបស់ខ្លួន។ នៅពេលដែលស្ត្រីមានភាពឯករាជ្យផ្នែកហិរញ្ញវត្ថុក្នុងកម្រិតមួយ ពួកគេអាចសម្រេចចិត្តដោយខ្លួនឯងពាក់ព័ន្ធនឹងការថែទាំសុខភាពនិងសុវត្ថិភាពផ្ទាល់ខ្លួន។

## ការប្រឆាំងនឹងហិង្សាផ្នែកយេនឌ័រនៅតាមសាលារៀន

នៅក្នុងសហគមន៍ខ្លះ, គ្រូបង្រៀន បុគ្គលិកសាលារៀន សិស្ស និងឪពុកម្តាយ សហការគ្នាដើម្បីធ្វើឲ្យសាលារៀនមានសុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា។ ពួកគេព្រមព្រៀងគ្នាក្នុងការប្រឆាំងយ៉ាងសកម្មទៅនឹងគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា, រួមទាំងការធ្វើបាបមិត្តរួមថ្នាក់ និងហិង្សាផ្លូវភេទ, និងក្នុងការបង្កើតនូវបរិស្ថានសាលារៀនមួយដែលមនុស្សគ្រប់គ្នាខិតខំធ្វើជាជនគំរូ។

### កម្មវិធីសាលារៀនមួយ ដើម្បីចូលរួមបញ្ឈប់វដ្តនៃអំពើហិង្សា

ឃីបេរ៉ា(Kibera) គឺជាសហគមន៍ដ៏ធំនិងអ៊ូអរមួយ នៅក្នុងទីក្រុងណៃរ៉ូប៊ី (Nairobi) នៃប្រទេសកេនយ៉ា។ ប្រជាជនភាគច្រើនដែលរស់នៅទីនោះ មានជីវភាពក្រីក្រខ្លាំង ហើយហិង្សាក្នុងគ្រួសារគឺជាបញ្ហាកើតឡើងញឹកញាប់។ ក្រុមអភិវឌ្ឍសហគមន៍មួយដែលមានឈ្មោះថា រេម៉ាតាអាឡា (Rehma Ta Allah) ធ្វើការងារនៅតាមសាលារៀនដើម្បីជួយដល់សិស្សទាំងឡាយឲ្យស្វែងយល់ថា អំពើហិង្សាលើស្ត្រីគឺមិនមែនជាបញ្ហាធម្មតាទេ ហើយគេអាចបញ្ឈប់វាបាន។ កម្មវិធីរបស់ពួកគេរួមមាន ការសម្តែងតួ ល្ខោនខ្លី និងសកម្មភាពដទៃទៀតដែលបង្រៀនសិស្សសាលាអំពីវដ្តនៃអំពើហិង្សា និងពីរបៀបដែលវាបង្កគ្រោះថ្នាក់ដល់ពួកគេនិងសហគមន៍ទាំងមូល។ វគ្គពិភាក្សា ផ្តល់ការជំរុញឲ្យសិស្សជជែកដោយសេរីអំពីស្ថានភាពហិង្សាដែលពួកគេធ្លាប់បានឃើញ ឬជួបប្រទះ។ ពួកគេក៏ត្រូវបានស្នើឲ្យគូររូបភាពបង្ហាញពីស្ថានភាពហិង្សា បន្ទាប់មកពិភាក្សាថាតើរូបភាពបង្ហាញអ្វីខ្លះ ហើយពួកគេមានអារម្មណ៍បែបណាចំពោះរូបភាពទាំងនោះ។ កម្មវិធីនេះបានជួយឲ្យគ្រូបង្រៀន អាចសម្គាល់ថាតើសិស្សណាម្នាក់ឬសមាជិកគ្រួសារ កំពុងរងនូវអំពើបំពាន ដើម្បីឲ្យពួកគាត់ត្រៀមលក្ខណៈផ្តល់ការគាំទ្រដល់កុមារនោះនៅពេលស្ថានភាពលំបាកកើតឡើង។

# កិច្ចប្រឹងប្រែងធ្វើឲ្យប្រព័ន្ធយុត្តិធម៌ដំណើរការ ដើម្បីបញ្ឈប់អំពើហិង្សា

ប្រព័ន្ធយុត្តិធម៌ ពោលគឺច្បាប់ តុលាការ ប៉ូលិស និងអាជ្ញាធរដទៃទៀត មានតួនាទីធ្វើការងារជាមួយគ្នា ដើម្បីគាំទ្រដល់សិទ្ធិរបស់ស្ត្រីនិងរបស់មនុស្សគ្រប់រូប ដើម្បីឲ្យពួកគេរស់នៅដោយសេរីភាព និងមិនរងនូវអំពើហិង្សា។ ប៉ុន្តែសេរីភាពបែបនេះគឺជាការកម្រណាស់ ហើយហិង្សាផ្នែកយេនឌ័រនៅតែជាបញ្ហាដែលកើតឡើងជាញឹកញាប់ដដែល។ នៅប្រទេសខ្លះ ច្បាប់ដែលការពារស្ត្រី គឺមិនត្រូវបានគេយកអនុវត្តទេ ហើយប្រព័ន្ធយុត្តិធម៌បែរជាធ្វើឲ្យជនរងគ្រោះ មានអារម្មណ៍ថាអំពើហិង្សាដែលកើតឡើងមកលើរូបគេ គឺជាកំហុសរបស់ពួកគេខ្លួនឯងទៅវិញ។ នៅប្រទេសខ្លះទៀត ច្បាប់ប្រឆាំងនឹងអំពើហិង្សាផ្នែកយេនឌ័រ គឺមិនមានចែងឡើយ, ឬមានមិនគ្រប់គ្រាន់ ហើយចាំបាច់ត្រូវកែលម្អថែមទៀត។

## សិក្សាពីការការពារផ្លូវច្បាប់

ច្បាប់ តុលាការ ប៉ូលិស និងអាជ្ញាធរដទៃទៀត សុទ្ធតែដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអំពើហិង្សានៅក្នុងសហគមន៍មួយ។ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅក្នុងផ្នែកនីមួយៗនៃប្រព័ន្ធយុត្តិធម៌ ច្រើនតែមិនសូវច្បាស់លាស់។ ដើម្បីប្រយុទ្ធនឹងអំពើហិង្សាផ្នែកយេនឌ័រឲ្យកាន់តែមានប្រសិទ្ធភាព យើងត្រូវរៀនសូត្រអំពីច្បាប់ការពារដែលមានស្រាប់ ព្រមទាំងពីចន្លោះប្រហោងរវាងច្បាប់លើក្រដាស និងការអនុវត្តជាក់ស្តែង។ បន្ទាប់មកយើងអាចធ្វើកិច្ចការទៅលើរបៀបកែលម្អច្បាប់ កែលម្អការអនុវត្ត និងកែប្រែឥរិយាបថ។

ក្រុមការងារអាចប្រើប្រាស់សកម្មភាពបន្ទាប់នេះ ដើម្បីរៀនសូត្រពីតួនាទីរបស់អាជ្ញាធរក្នុងការគាំទ្រដល់ជនរងគ្រោះនៃអំពើហិង្សាផ្នែកយេនឌ័រ។

សកម្មភាព

## ការស៊ើបអង្កេតជាក្រុមអំពីតួនាទីនៃអាជ្ញាធរមូលដ្ឋាន

**ត្រៀមលក្ខណៈ**ជាមុន ដោយសិក្សាពីច្បាប់ឲ្យបានច្រើនបំផុត។ ប្រសិនបើអាច ចូរស្វែងរកនរណាម្នាក់ដែលមានចំណេះដឹងផ្នែកប្រព័ន្ធយុត្តិធម៌ ឲ្យផ្តល់ការគាំទ្រដល់អ្នក និងចូលរួមក្នុងការប្រជុំ ធ្វើជាមនុស្សធនធាន។ ដំណើរការនេះមានលទ្ធផលល្អបំផុត ប្រសិនបើអ្នកអាចអញ្ជើញអាជ្ញាធរមកពីមូលដ្ឋានផ្សេងៗគ្នា ដែលពួកគាត់បើកចំហរក្នុងការជជែកជាមួយក្រុមរបស់អ្នក។

❶ តើអ្នកអាចស្វែងរកនរណា? ដើម្បីចាប់ផ្តើមដំណើរការនេះ ចូរប្រាប់ឲ្យក្រុមធ្វើការពិភាក្សាលើសំណួរមួយនេះ ៖ "តើអ្នកគួរតែទៅរកអ្នកណា ប្រសិនបើមានករណីហិង្សាកើតឡើងលើស្ត្រីក្នុងសហគមន៍របស់អ្នក?"

គូសតារាងដូចខាងក្រោមនៅលើផ្ទាំងក្រដាសធំមួយដែលគ្រប់គ្នាអាចមើលឃើញ។ នៅក្នុងជួរឈរទីមួយ សរសេរចូលនូវឈ្មោះអាជ្ញាធរមកពីមូលដ្ឋានផ្សេងៗដែលក្រុមបានលើកឡើង។ សួរមនុស្សធនធានឲ្យបន្ថែមឈ្មោះដទៃទៀត បើក្រុមបានមើលរំលង។

| *អាជ្ញាធរ* | *តួនាទី (តើគាត់ធ្វើអ្វីខ្លះ?)* | *តើគាត់មិនអាចធ្វើអ្វីខ្លះបាន? ហេតុអ្វី?* | *តើគាត់ត្រូវធ្វើអ្វីខ្លះទៀត?* |
|---|---|---|---|
| *ប៉ូលិស* | | | |
| *អភិបាលក្រុង អភិបាលខណ្ឌ* | | | |
| *វេជ្ជបណ្ឌិត ឬបុគ្គលិកសុខាភិបាលដទៃទៀត* | | | |
| *ចៅក្រម ឬមន្ត្រីតុលាការ* | | | |
| *មន្ត្រីក្រសួងកិច្ចការនារី* | | | |

❷ ពន្យល់ថាគោលបំណងនៃការស៊ើបអង្កេតជាក្រុមនេះ គឺដើម្បីសិក្សាថាតើអាជ្ញាធរនីមួយៗមានតួនាទីអ្វីខ្លះក្នុងការបញ្ឈប់ហិង្សាផ្នែកយេនឌ័រ តាមរយៈការឆ្លើយនឹងសំណួរទាំងនេះ ៖

- តើសព្វថ្ងៃអាជ្ញាធរនីមួយៗធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាហិង្សាលើស្ត្រី, លើអ្នកស្រឡាញ់ភេទដូចគ្នា-ភេទទាំង២ និងអ្នកមានភេទទី៣?
- តើអ្វីខ្លះដែលពួកគេមិនធ្វើ? អ្វីខ្លះដែលពួកគេមិនអាចធ្វើ? ហេតុអ្វី?
- តើពួកគេគួរធ្វើខ្លះផ្សេងទៀតដើម្បីដោះស្រាយបញ្ហាហិង្សាប្រភេទនេះ?

## សកម្មភាព ការស៊ើបអង្កេតជាក្រុមអំពីតួនាទីនៃអាជ្ញាធរមូលដ្ឋាន (ត)

ឲ្យក្រុមទាំងមូលបំបែកជាក្រុមតូចៗ។ ពន្យល់ថាក្រុមនីមួយៗត្រូវសិក្សាបន្ថែមពីតួនាទីរបស់អាជ្ញាធរម្នាក់ក្នុងចំណោមខាងលើ ហើយត្រូវប្រមូលព័ត៌មានដើម្បីឆ្លើយសំណួរទាំងនេះ។ ពួកគេត្រូវចែករំលែកព័ត៌មានរបស់ខ្លួនទៅកាន់ក្រុមទាំងមូលនៅពេលប្រជុំលើកក្រោយ។

3 ស៊ើបអង្កេត! ក្រុមនីមួយៗអាចត្រូវការពេលជាច្រើនសប្តាហ៍ ដើម្បីប្រមូលព័ត៌មានដែលត្រូវការ តាមរយៈការធ្វើសម្ភាសន៍ និងការស្រាវជ្រាវផ្សេងៗ។ ឧទាហរណ៍ ពួកគេអាចព្យាយាមធ្វើសម្ភាសន៍ជាមួយមនុស្សមួយចំនួននៅក្នុងស្ថាប័ននីមួយៗដើម្បីទទួលបានគំនិតផ្សេងៗគ្នា។ ពួកគេក៏អាចធ្វើសម្ភាសន៍ជាមួយស្ត្រីដែលធ្លាប់ស្វែងរកជំនួយពីអាជ្ញាធរដើម្បីទាមទារយុត្តិធម៌ផងដែរ។ ព័ត៌មានថ្មីៗ និងកំណត់ត្រារបស់តុលាការ អាចជួយពន្យល់ថាតើអាជ្ញាធរធ្វើអ្វីខ្លះ និងមិនធ្វើអ្វីខ្លះ។

4 នៅពេលក្រុមបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន អញ្ជើញពួកគេឲ្យចូលរួមការប្រជុំឡើងវិញដើម្បីរាយការណ៍ជូនក្រុមទាំងមូល។ ត្រូវផ្តល់ពេលវេលាឲ្យច្រើនដល់ក្រុមនីមួយៗធ្វើបទបង្ហាញ និងដើម្បីឲ្យមានពេលសម្រាប់សួរសំណួរ។




5 ដើម្បីបញ្ចប់ ចូរប្រាប់ក្រុមឲ្យធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានរៀនសូត្រពីដំណើរការនេះ ហើយអ្វីខ្លះដែលជាចំណុចផ្តោតសំខាន់នៅក្នុងជំហានបន្ទាប់ ដើម្បីឈានទៅដល់ការកែលម្អប្រព័ន្ធយុត្តិធម៌។ ឧទាហរណ៍ ពួកគេអាចផ្តោតសំខាន់ទៅលើការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន អំពីតួនាទីរបស់អាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយករណីហិង្សាលើស្ត្រី។ ឬម្យ៉ាងទៀតពួកគេអាចព្យាយាមជួយសម្រួលដល់ក្រុមស្រឡាញ់ភេទដូចគ្នា-ភេទទាំង២និងអ្នកមានភេទទី៣ឲ្យមានលទ្ធភាពរៀបចំបណ្តឹងទៅប៉ូលិស។

ដើម្បីបង្កើតផែនការ អ្នកអាចបន្តអនុវត្តសកម្មភាព "ធ្វើផែនទីអំណាច" (ទំព័រ 284) បន្ទាប់ពីនេះ។

# ធ្វើការងារជាមួយតុលាការនិងប៉ូលិស

ប្រព័ន្ធយុត្តិធម៌ជាការគាំទ្រដ៏មានប្រសិទ្ធភាពនៅពេលដែលចៅក្រម មេធាវី មន្ត្រីតុលាការ និងប៉ូលិស ទទួលស្គាល់ថាស្ត្រី និងក្រុមស្រឡាញ់ភេទដូចគ្នា-ភេទទាំង២និងអ្នកមានភេទទី៣ មិនទទួលបានការគោរពសិទ្ធិដូចអ្នកដទៃទេ ហើយអាជ្ញាធរត្រូវតែធ្វើការងារដើម្បីការពារសិទ្ធិរបស់មនុស្សគ្រប់រូប។ ជាញឹកញាប់ ការរួមបញ្ចូលអាជ្ញាធរទាំងនោះទៅក្នុងកិច្ចប្រឹងប្រែងកែលម្អប្រព័ន្ធ គឺត្រូវការពេលវេលា យុទ្ធសាស្ត្រចម្រុះ និងការប្រជុំជាច្រើនលើកច្រើនសារ។ អ្នកគួរតែជជែកជាមួយអ្នកដឹកនាំសហគមន៍ ដើម្បីស្វែងរកមនុស្សនៅក្នុងប្រព័ន្ធយុត្តិធម៌ ដែលពួកគាត់ទំនងជានឹងស្តាប់ហើយគាំទ្រដល់សំណើរបស់អ្នក។

នេះជាឧទាហរណ៍ខ្លះៗអំពីមធ្យោបាយដែលអ្នកអាចកែលម្អប្រព័ន្ធយុត្តិធម៌ ៖



**អង្គភាពប៉ូលិសស្រី។** ជាញឹកញាប់ ស្ត្រីពិបាកនឹងនិយាយជាមួយប៉ូលិសប្រុស នៅពេលដែលពួកគាត់រាយការណ៍ពីករណីរំលោភផ្លូវភេទ ឬហិង្សាក្នុងគ្រួសារ។ នៅទសវត្សរ៍៨០ អង្គការស្ត្រីទាំងឡាយនៅក្នុងប្រទេសប្រេស៊ីល បានធ្វើការតស៊ូមតិដើម្បីទាមទារឲ្យមានអង្គភាពប៉ូលិសដែលមានតែស្ត្រី។ អង្គភាពប៉ូលិសដែលមានតែស្ត្រី ត្រូវបានបង្កើតឡើងជាលើកដំបូងនៅឆ្នាំ១៩៨៥ ហើយសព្វថ្ងៃមានប្រទេសជាច្រើនកំពុងប្រើប្រាស់គំរូនេះ។ បុគ្គលិកសង្គមច្រើនតែធ្វើការងារជាមួយប៉ូលិស ដើម្បីជួយស្ត្រីឲ្យយល់ដឹងពីសិទ្ធិរបស់ខ្លួន ធ្វើការសម្រេចចិត្ត ព្រមទាំងទទួលការថែទាំសុខភាពនិងសេវាផ្សេងៗទៀត។

**ប៉ូលិសទទួលការបណ្តុះបណ្តាលអំពីហិង្សាផ្នែកយេនឌ័រ។** សកម្មជនក្នុងសហគមន៍ក៏អាចផ្តល់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ផងដែរ អំពីហិង្សាផ្នែកយេនឌ័រ។ មានមន្ត្រីប៉ូលិសខ្លះមិនអនុវត្តច្បាប់ទៅលើអំពើហិង្សាក្នុងគ្រួសារ ឬហិង្សាលើអ្នកស្រឡាញ់ភេទដូចគ្នាទេ។ ពួកគេអាចនឹងបដិសេធថាគ្មានអំពើហិង្សាកើតឡើងទេ។ ដើម្បីផ្លាស់ប្តូរឥរិយាបថចាស់ទាំងនេះ មន្ត្រីប៉ូលិសទាំងនោះត្រូវការឱកាសដើម្បីស្វែងយល់ពីបញ្ហានេះបន្ថែមទៀត។

**តុលាការផ្នែកហិង្សាក្នុងគ្រួសារ។** ជាញឹកញាប់ ស្ត្រីមានការភ័យខ្លាច មិនហ៊ានរាយការណ៍ទៅប៉ូលិសអំពីប្តីរបស់គាត់ដែលប្រើអំពើហិង្សានោះទេ ព្រោះពួកគាត់ពឹងផ្អែកលើប្តីដែលជាអ្នករកប្រាក់ចំណូល។ ប្រសិនបើប្តីរបស់គាត់ត្រូវបានចាប់បញ្ចូលគុក ស្ត្រីអាចបាត់បង់ផ្ទះ ឬធនធានផ្សេងៗទៀត។ ប៉ុន្តែបើមិនដូច្នោះទេ ប្តីគាត់អាចនឹងបង្កហិង្សាទៅលើគាត់កាន់តែធ្ងន់ធ្ងរ។ ស្ត្រីដែលជាប់នៅក្នុងស្ថានភាពអំពើហិង្សាក្នុងគ្រួសារ អាចនិយាយពីការបំពានបាន ប៉ុន្តែមិនអាចបែកគ្នាហើយដើរចេញពីប្តីដែលប្រើហិង្សាដោយងាយនោះទេ។ វាអាចបណ្តាលឲ្យមានបណ្តឹងជាច្រើនលើកច្រើនសារ ប៉ុន្តែវាមិនបានបញ្ឈប់អំពើហិង្សានោះទេ។ នៅសហរដ្ឋអាមេរិក ប្រព័ន្ធយុត្តិធម៌តាមរដ្ឋមួយចំនួនបានឆ្លើយតបចំពោះវដ្តនៃអំពើហិង្សានេះ តាមរយៈការបង្កើតជាតុលាការផ្នែកហិង្សាក្នុងគ្រួសារ។



នៅពេលដែលមានបណ្ដឹងរបស់ស្ត្រី មកដល់តុលាការភ្លាម តុលាការផ្នែកហិង្សាក្នុងគ្រួសារនេះ នឹងផ្ដល់ជូននូវសេវាសង្គមផ្សេងៗដូចជា ផ្ទះស្នាក់អាស្រ័យ និងការបណ្ដុះបណ្ដាលការងារដល់ស្ត្រីជាដើម។ ស្ត្រីក៏ទទួលបាននូវការបណ្ដុះបណ្ដាលផងដែរអំពីការរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងបង្កើតផែនការរត់គេចពីស្ថានភាពហិង្សា។ (សូមមើល ការជួយជនរស់រានឲ្យគេចចេញពីអំពើហិង្សាក្នុងគ្រួសារ, ទំព័រ 166)។ តុលាការទាំងនេះក៏ជួយរក្សាសុវត្ថិភាពដល់ស្ត្រីផងដែរ ក្នុងពេលនិងក្រោយពេលកិច្ចដំណើរការផ្លូវច្បាប់ តាមរយៈការឃ្លាំមើលឥរិយាបថរបស់ជនបំពាន។ យុទ្ធសាស្ត្រនេះធ្វើឲ្យដំណើរការតុលាការប្រព្រឹត្តទៅបានឆាប់រហ័ស ហើយអនុញ្ញាតឲ្យជនរស់រាន មានលទ្ធភាពចាកចេញពីទំនាក់ទំនងហិង្សា ដើម្បីទទួលបានជីវិតល្អប្រសើរ។

**យុត្តិធម៌បែបសម្របសម្រួល។** នៅពេលដែលក្រុមមនុស្សក្នុងសហគមន៍ ជួយជនដែលរស់រានពីអំពើហិង្សាក្នុងគ្រួសារឬការវាយដំជនស្រឡាញ់ភេទដូចគ្នា, ឲ្យប្រឈម និងចរចារជាមួយជនបំពាន នោះគេហៅថា យុត្តិធម៌បែបសម្របសម្រួល។ ដើម្បីឲ្យសហគមន៍មួយចូលរួមទទួលខុសត្រូវលើបញ្ហានេះ គេត្រូវការពេលវេលា និងការបណ្ដុះបណ្ដាលជាច្រើន។ វាមានប្រសិទ្ធភាពបំផុតនៅពេលដែលមានការគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍។

**ប្រព័ន្ធយុត្តិធម៌ឯករាជ្យ។** នៅទីក្រុងផ្សេងៗគ្នានៃប្រទេសឥណ្ឌា មានក្រុមមួយឈ្មោះថា ប៊ីអឹមអឹមអេ (Bharatiya Muslim Mahila Andolan (BMMA)) បានបង្កើតជាប្រព័ន្ធយុត្តិធម៌របស់ខ្លួនមួយសម្រាប់ដោះស្រាយបញ្ហាផ្លូវច្បាប់របស់ស្ត្រី។ កាលពីមុន ករណីលែងលះនិងចិញ្ចឹមកូន ត្រូវបានដោះស្រាយតាមរយៈប្រព័ន្ធរបស់រដ្ឋ ឬតាមរយៈតុលាការ Sharia (ប្រើច្បាប់អ៊ិស្លាម) ដែលដំណើរការដោយបុរសទាំងស្រុង។ តុលាការនេះកម្រកាត់សេចក្ដីឲ្យ ស្ត្រីជាអ្នកឈ្នះណាស់ ហើយជាញឹកញាប់ស្ត្រីបានបាត់បង់ការគាំទ្រហិរញ្ញវត្ថុសម្រាប់ខ្លួនគាត់និងកូន។ ក្រុមប៊ីអឹមអឹមអេ ធ្វើកិច្ចការដើម្បីបង្កើតជាច្បាប់ថ្នាក់ជាតិដែលពង្រឹងដល់ប្រព័ន្ធការពារស្ត្រីដែលមានស្រាប់ដែលប្រព័ន្ធនេះប្រើច្បាប់អ៊ិស្លាម, ក៏ដូចជាផ្ដល់ការគាំទ្រផ្លូវច្បាប់ដល់ស្ត្រីដែលសម្រេចចិត្តប្រើប្រាស់ប្រព័ន្ធតុលាការរបស់រដ្ឋផងដែរ។




Freda Adler,
អ្នកសិក្សាផ្នែកឧក្រិដ្ឋកម្ម

## ច្បាប់សិទ្ធិមនុស្សអាចជួយបាន

នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ អំពើហិង្សាផ្លូវភេទដែលធ្វើឡើងជាផ្នែកមួយនៃការវាយប្រហារទៅលើជនស៊ីវិលមួយក្រុមត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មានន័យថា ការខូចខាតដែលធ្វើឡើងចំពោះមនុស្សមួយក្រុម គឺជាភាពអយុត្តិធម៌សម្រាប់មនុស្សទាំងអស់។ មានក្រុមការងារជាច្រើន ប្រើប្រាស់ច្បាប់សិទ្ធិមនុស្សនៅពេលពួកគេទាមទារយុត្តិធម៌ពីតុលាការឬរដ្ឋាភិបាលក្នុងស្រុក។ (សម្រាប់ព័ត៌មានបន្ថែម សូមមើលឧបសម្ព័ន្ធ ក ៖ ការតស៊ូមតិដើម្បីសិទ្ធិស្ត្រី ដោយប្រើប្រាស់ច្បាប់អន្តរជាតិ)។

# ការរៀបចំដើម្បីទាមទារយុត្តិធម៌សម្រាប់ជនដែលរួចរស់រាន

ទោះបីជាអ្នកខិតខំប្រឹងប្រែងពន្យល់ណែនាំដល់ប៉ូលិស ឬបង្កើតប្រព័ន្ធយុត្តិធម៌បែបសម្របសម្រួលយ៉ាងណាក៏ដោយ ក៏អ្នកនៅតែត្រូវកៀរគរការគាំទ្រក្នុងសហគមន៍ជានិច្ច។ ប្រសិនបើអ្នកអាចចលនាសហគមន៍ឲ្យស្វែងយល់ និងចាត់វិធានលើបញ្ហាហិង្សាផ្នែកយេនឌ័រ នោះអ្នកនឹងទទួលបាននូវឧបករណ៍ដ៏ខ្លាំងក្លាមួយសម្រាប់នាំយកយុត្តិធម៌ជូនជនដែលនៅរស់រានទាំងឡាយ។ ឧទាហរណ៍ ប្រសិនបើមានការគាំទ្រក្នុងមូលដ្ឋានយ៉ាងរឹងមាំ អ្នកអាចធ្វើយុទ្ធនាការប្រឆាំងនឹងចៅក្រមដែលតែងតែរើសអើងចំពោះស្ត្រី និងជនស្រឡាញ់ភេទដូចគ្នា-ភេទទាំង២និងជនមានភេទទី៣ ដោយបង្ខំឲ្យចៅក្រមនោះកែប្រែផ្នត់គំនិត ឬចុះចេញពីតំណែង។ អ្នកក៏អាចចលនាសហគមន៍របស់អ្នកឲ្យដាក់សម្ពាធលើមណ្ឌលសុខភាពមួយ ឲ្យពួកគេកែលម្អពិធីសារកត់ត្រាព័ត៌មានចំពោះករណីរំលោភបំពានលើស្ត្រី។



នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ត្រីនៅក្រុងហុងកុង បានចូលរួមជាមួយមនុស្ស១កោដិនាក់ មកពីប្រទេស ចំនួន២០៧ ក្រោកឈរនិងរាំដើម្បីទាមទារឲ្យមាន ការបញ្ចប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ សម្រាប់ ព័ត៌មានបន្ថែមអំពីគម្រោង "ក្រោកឈរ១កោដិនាក់ ដើម្បីយុត្តិធម៌" សូមចូលទៅវិបសាយ ៖ www.onebillionrising.org

តាមរយៈការភ្ជាប់ជាមួយនឹងចលនាជាសកលប្រឆាំងនឹងអំពើហិង្សា អ្នកអាចពង្រឹងការរៀបចំរបស់អ្នក និងទទួលបាន ចំណាប់អារម្មណ៍កាន់តែច្រើនពីប្រព័ន្ធព័ត៌មាន។ គម្រោង V-Day ដែលជាកិច្ចប្រឹងប្រែងជាសកលដើម្បីបញ្ចប់អំពើហិង្សាលើ ស្ត្រីនិងក្មេងស្រី ធ្វើការបង្កើនការយល់ដឹងនិងប្រមូលមូលនីធិដើម្បីជួយដល់សកម្មភាពប្រឆាំងនឹងអំពើហិង្សា។ ទិវាអន្តរជាតិ ប្រឆាំងនឹងការស្អប់ជនស្រឡាញ់ភេទដូចគ្នា គឺជាឱកាសមួយទៀតដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ដ៏ធំដែលមានចំណាប់អារម្មណ៍ ខ្លាំងពីប្រព័ន្ធផ្សព្វផ្សាយ។ ព្រឹត្តិការណ៍នេះប្រារព្ធឡើងនៅថ្ងៃទី១៧ ខែឧសភា ដើម្បីជាការអបអរដល់ថ្ងៃដែលអង្គការសុខភាព ពិភពលោកបានលុបការស្រឡាញ់ភេទដូចគ្នា ចេញពីបញ្ជីជំងឺផ្លូវចិត្ត។ ព្រឹត្តិការណ៍នេះជួយលើកកម្ពស់ការយល់ដឹងអំពីបញ្ហា របស់មនុស្សស្រឡាញ់ភេទដូចគ្នា-ភេទទាំង២និងមនុស្សភេទទី៣ នៅក្នុងសហគមន៍ កន្លែងការងារ និងក្នុងគ្រួសាររបស់ពួកគេ។

## ការតវ៉ានៅប្រទេសឥណ្ឌា ទាមទារឱ្យបញ្ចប់អំពើហិង្សាលើស្ត្រី

នៅខែធ្នូ ឆ្នាំ២០១២ នៅទីក្រុងញូឌេលី នៃប្រទេសឥណ្ឌា មាននារីម្នាក់អាយុ២៣ឆ្នាំ ត្រូវបានបុរស៦ម្នាក់វាយ ប្រហារ និងចាប់រំលោភនៅលើរថយន្តក្រុងមួយ។ បុរសម្នាក់ជាមិត្តភក្តិរបស់នាង ដែលបានព្យាយាមការពារនាង ត្រូវ ក្រុមអន្ធពាលវាយឲ្យរងរបួសជាទម្ងន់ ហើយបន្ទាប់មកពួកគេក៏បោះទម្លាក់នាងនិងមិត្តភក្តិចេញពីរថយន្តក្រុងនោះ។ អ្នកដំណើរបានឃើញពួកគេនៅលើដងផ្លូវ រួចក៏យកពួកគេទៅមន្ទីរពេទ្យ។ ២សប្តាហ៍ក្រោយ នារីនោះក៏ស្លាប់ដោយសារ របួសធ្ងន់ធ្ងរពេក។ ព័ត៌មានអំពីការវាយប្រហារនេះ បានផ្សព្វផ្សាយពាសពេញទីក្រុង និងទូទាំងប្រទេស។ ពីរបីថ្ងៃ បន្ទាប់មក អ្នកតវ៉ារាប់ពាន់នាក់បានប្រមូលផ្តុំគ្នានៅទីក្រុងញូឌេលី និងក្រុងដទៃទៀត ដើម្បីតវ៉ាប្រឆាំងនឹងដំណើរការដ៏ យឺតយ៉ាវរបស់រដ្ឋាភិបាលទៅលើអំពើរំលោភផ្លូវភេទ និងដើម្បីទាមទារឲ្យបញ្ចប់អំពើហិង្សាផ្លូវភេទនៅក្នុងប្រទេសឥណ្ឌា ទាំងមូល។

ក្រុមស្ត្រីនិងអង្គការដទៃទៀតនៅប្រទេសឥណ្ឌា បាននិយាយជាសាធារណៈប្រឆាំងនឹងការរំលោភផ្លូវភេទ និង រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី។ ប៉ុន្តែការតវ៉ាជាទ្រង់ទ្រាយធំ និងការគាបសង្កត់ពីប៉ូលិស បានទាញចំណាប់ អារម្មណ៍កាន់តែច្រើនពីប្រព័ន្ធផ្សព្វផ្សាយ។ មានអ្នកតវ៉ាជាច្រើនបានរាយការណ៍ពីបទពិសោធន៍ផ្ទាល់ខ្លួននិងរបស់គ្រួសារ អំពីការបំពានផ្លូវភេទ និងការរំលោភនានា។ ពួកគេខឹងសម្បារនឹងប៉ូលិសនិងតុលាការដែលបានច្រានចោលពាក្យបណ្តឹង របស់គាត់ ហើយមិនអាចដាក់ទោសជនល្មើសបាន ប៉ុន្តែពួកគេមិនដែលគិតថាអាចនិយាយជាសាធារណៈ ឬទាមទាររក យុត្តិធម៌បាននោះទេ។




ទាំងបុរសនិងស្ត្រី បានចូលរួមក្នុងការតវ៉ាដើម្បីថ្កោលទោសទៅលើឥរិយាបទចំពោះស្ត្រី ដែលគិតថាស្ត្រីគឺជាវត្ថុមួយដែលបុរសអាចប្រើប្រាស់តាមត្រូវការ។ អ្នកតវ៉ាបានធ្វើការបញ្ជាក់ថា ស្ត្រីមិនមែនជាអ្នកដែលត្រូវទទួលការបន្ទោសទេ នៅពេលដែលមានការបំពាននិងហិង្សាមកលើរូបគាត់។ មានក្រុមបុរសមួយក្រុមបានបង្ហាញសាមគ្គីភាពជាមួយស្ត្រី ដោយបានស្លៀកពាក់ជាស្ត្រីរយៈពេលមួយថ្ងៃ ដើម្បីទាញចំណាប់អារម្មណ៍ពីប្រជាជន ឲ្យស្វែងយល់ពីស្ថានភាពរបស់ស្ត្រីនៅក្នុងទីសាធារណៈ។

មនុស្សនៅទូទាំងពិភពលោកបានទទួលសារពីអ្នកតវ៉ា។ ពួកគេទាមទារឲ្យមានការចាប់ខ្លួនជាបន្ទាន់ និងកាត់ទោសលើករណីរំលោភនិងហិង្សា, រឹតបន្តឹងច្បាប់ និងអនុវត្តច្បាប់លើបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងយេនឌ័រ, ព្រមទាំងផ្តល់ការធ្វើដំណើរប្រកបដោយសុវត្ថិភាពដល់ស្ត្រីគ្រប់រូប។

ចំណាប់អារម្មណ៍ជាអន្តរជាតិ រួមផ្សំជាមួយនឹងកិច្ចប្រឹងប្រែងក្នុងប្រទេស បានបង្កើតជាសម្ពាធដើម្បីការផ្លាស់ប្តូរ។ ក្រុងមួយចំនួនបានរឹតបន្តឹងច្បាប់ស្តីពីការរំលោភផ្លូវភេទ ព្រមទាំងសន្យាផ្តល់ជូនសេវាថ្មី។ រដ្ឋាភិបាលបានតែងតាំងគណៈកម្មាធិការជាន់ខ្ពស់ដើម្បីផ្តល់អនុសាសន៍អំពីការកែប្រែច្បាប់។ ក្រុមស្ត្រីមានក្តីសង្ឃឹមនៅពេលដែលមតិណែនាំជាច្រើនរបស់ពួកគេដែលបានដាក់ជូនគណៈកម្មាធិការ ត្រូវបានបញ្ចូលក្នុងរបាយការណ៍ចុងក្រោយ។ ប៉ុន្តែក្រោយមកពួកគេក៏អស់សង្ឃឹមជាថ្មីនៅពេលដែលរដ្ឋាភិបាលបានចេញបទបញ្ញត្តិមួយដែលមិនអើពើនឹងរបាយការណ៍នោះ ហើយមិនបានថ្កោលទោសចំពោះអំពើហិង្សាផ្អែកយេនឌ័រគ្រប់ទម្រង់នោះទេ។ បទបញ្ញត្តិនោះធ្វើឡើងក្នុងចេតនាបន្ថយកម្តៅការតវ៉ា ប៉ុន្តែផ្ទុយទៅវិញវាបានជំរុញឲ្យផ្ទុះការតវ៉ាសារជាថ្មីឡើងវិញ។

ប្រជាជននៅប្រទេសឥណ្ឌាបន្តការនិយាយជាសាធារណៈអំពីអំពើហិង្សាផ្អែកយេនឌ័រ។ បច្ចុប្បន្នប្រព័ន្ធព័ត៌មានជាតិនិងអន្តរជាតិ រាយការណ៍អំពីករណីរំលោភបំពានផ្សេងៗទៀត។ ក្រុមតស៊ូមតិ បន្តដាក់សម្ពាធលើរដ្ឋាភិបាលឲ្យរឹតបន្តឹងច្បាប់ប្រឆាំងនឹងការរំលោភផ្លូវភេទ ព្រមទាំងបង្កើនការអនុវត្តច្បាប់បន្ថែមទៀត។ កិច្ចប្រឹងប្រែងទាំងនេះបានផ្លាស់ប្តូរពីវប្បធម៌នៃភាពស្ងាត់ស្ងៀមចំពោះហិង្សាផ្អែកយេនឌ័រ ទៅជាវប្បធម៌នៃសំឡេងទាមទារការផ្លាស់ប្តូរ។

ការទាញចំណាប់អារម្មណ៍មហាជនមកលើបញ្ហាហិង្សាផ្អែកយេនឌ័រ អាចជាកិច្ចការដ៏លំបាកមួយ ជាពិសេសនៅទីកន្លែងដែលបញ្ហានេះត្រូវបានគេព្រងើយកន្តើយជាយូរមកហើយ។ ប៉ុន្តែនៅពេលដែលមានមនុស្សរាប់ពាន់នាក់ដង្ហែរក្បួនថ្កោលទោសអំពើរំលោភនិងហិង្សាផ្លូវភេទ នោះវាក្លាយជាបញ្ហារបស់ពិភពលោកទាំងមូល ដោយមានការជួយផ្សព្វផ្សាយតាមទូរទស្សន៍ អ៊ីនធើនែត និងទូរស័ព្ទដៃ។ សូម្បីតែពេលខ្លះព័ត៌មានត្រូវបានរាយការណ៍មិនពេញលេញ ឬតែជ្រុងម្ខាងក៏ដោយ ក៏ពួកគេអាចលើកកម្ពស់ការយល់ដឹងពីបញ្ហានេះផងដែរ ព្រមទាំងបង្កើតឱកាសដើម្បីពិភាក្សានិងដេញដោលពីដំណោះស្រាយផ្សេងៗលើបញ្ហាហិង្សាផ្អែកយេនឌ័រ។